ភាពជាដៃគូផ្លូវ ហោះហើរអូស្ត្រាលី–អាស៊ីខាងកើត

**កិច្ចប្រជុំភាគីដៃគូលើកទី៤ នៅសង់ដូ សាធារណៈរដ្ឋកូរ៉េ**

**២៣ –២៤ ខែកុម្ភៈ ឆ្នាំ ២០១០**

**របាយការណ៍ (កំណត់ហេតុ) នៃកិច្ចប្រជុំភាគីដៃគូ លើកទី៤**

អ្នកចូលរួម:

**<u>តំណាងភាគីដៃគូ ចូលរួមក្នុងកិច្ចប្រជុំនេះមាន</u> :**

អង្គការក្រុមសិក្សាបាតសមុទ្រ អូស្ត្រាលី(Australasian Wader Studies Group): Ken Gosbell, Phil Straw (AWSG).

ប្រទេសអូស្ត្រាលី: Paul O’Neill, Dwayne Purdy

អង្គការជីវិតសត្វស្លាបអន្តរជាតិ : Noritaka Ichida, Simba Chan, Nobuhiko Kishimoto, Chin Aik Yeap

អនុសញ្ញាស្តីពីលេខាធិការដ្ឋានដ្ឋានប្រភេទដែលធ្វើទេសន្តរប្រវេសន៍ : Douglas Hykle, Bert Lenten

ប្រទេសឥណ្ឌូណេស៊ី : Agus Sriyadi Budi Sutito, Dewi Malia Prawiradilaga

មូលនិធិសត្វក្រៀលអន្តរជាតិ : James Harris

ប្រទេសជប៉ុន : Zuiten Tsukamoto, Naoki Nakayama

ប្រទេសហ្វីលីពីន : Anson Tagtag

លេខាធិការដ្ឋានអនុសញ្ញារ៉ាមសារ : Jaej Mundkur (WI) តំណាងឱ្យ លោក Lew Young

សាធារណៈរដ្ឋកូរ៉េ : Yeon Man Jeong, Jeong-Won Choi, Sung-Hyeon Jang, Jin-Han Kim

ព្រះរាជាណាចក្រកម្ពុជា : លោក ស្រី ស៊ុនលាង និង លោក អ៊ុំង គឹមសាន

សាធារណៈរដ្ឋរុស្ស៊ី : Evegeny Syroechkovsky

សហរដ្ឋអាមេរិច : Douglas Alcorn

អង្គការដីសើមអន្តរជាតិ : Doug Watkins

អង្គការស្មោះត្រង់ដីសើម និងសត្វស្លាបទឹក (WWT) : Baz Hughes

អង្គការ WWF ៖ – Bena Smith, Satoshi Maekaw.

**ភាគីដៃគូដែលមានសក្តានុពល ដែលជាតំណាងនៅក្នុងកិច្ចប្រជុំ**

បង់ក្លាដែស: Tapan Kumar Dey

ម៉ាឡេស៊ី: Hasdi bin Hassan

ថៃឡង់ ៖ Nirawa Pipitsombat

មជ្ឈមណ្ឌលប្រចាំតំបន់រាមសារ អាស៊ីខាងកើត ៖ Seung-Oh Suh, Maurice Lineman

**អ្នកអង្គការអន្តរជាតិផ្សេងទៀត**

កិច្ចព្រមព្រៀងនៃការធ្វើទេសន្តរប្រវេសន៍ អាស៊ី អឺរ៉ុប–អាហ្វ្រិច៖ Bert Lenten

សមាគមអភិរក្សធម្មជាតិ និងជីវៈចម្រុះ (BANCA) ៖ ប្រទេសភូមា ៖ Lunn Zau

សមាគមជប៉ុន ដើម្បីការពារប្រភេទក្ងានព្រៃ ប្រទេសជប៉ុន ៖ Masayuki Kurechi

ក្រុមស្តារឡើងវិញបក្សីចំពុះស្លាបព្រា (Spoon-billed Sandpiper Recovery Team): Christoph Zockler

**អ្នកអង្គការក្នុងស្រុកផ្សេងទៀត**

សាធារណៈរដ្ឋកូរ៉េ ក្រសួងបរិស្ថាន ៖ In-Hye Jang, Hwa-Jung Kim, Gou-Nee Sung, Kyoung-Hee Oh

សាធារណៈរដ្ឋកូរ៉េ រដ្ឋាភិបាលក្រុង ៖ Incheon លោក Chang-Gu Lee, Sang-Ik Lee, Jung-Lyang Lee, Gwang-Chan An, Kuk-Hwa Lee.

សាធារណៈរដ្ឋកូរ៉េ មន្ត្រីរដ្ឋាភិបាលក្នុងតំបន់ផ្សេងទៀត ៖ Sung-Woo Han, Yoong-Goo Kim (រដ្ឋាភិបាលក្រុង Gunsan) , Min-Cheol Park, Chang-Hoe Kim (រដ្ឋាភិបាលក្រុង Seosan) In-Hwan Cha, Kil-Wook Yeo (រដ្ឋាភិបាលក្រុង Suncheon), Tae-Uk Kwon (រដ្ឋាភិបាលក្រុង Gumi)

អង្គការសត្វស្លាបកូរ៉េ ៖ Nial Moores, Meena Park, Seong-Uk Cho

មជ្ឈមណ្ឌល ៖ Gwanghwa Tidal Flat កូរ៉េ Sun-Rae Kim

សហប្រតិបត្តិការគ្រប់គ្រងសមុទ្រកូរ៉េ ៖ Namue Lee

បណ្តាញសត្វស្លាបទឹកកូរ៉េ (បណ្តាញសត្វក្រៀល) ៖ Gi-Sup Lee, Hwa-Youn Jeong

បណ្តាញអង្គការក្រៅរដ្ឋាភិបាលដីសើមកូរ៉េ ៖ In-Sik Lee

គម្រោងដីសើមកូរ៉េ ៖ Hyeon-Ju Lee

សាកលវិទ្យាល័យ : Kyeong-Hee កូរ៉េ

វិទ្យាស្ថានស្រាវជ្រាវឧទ្យានជាតិកូរ៉េ : Young-Soo Kwon

PGAI កូរ៉េ : Dong-Uk Han

មូលនិធិបរិស្ថានវ៉ាមសារ : Jin-Hae Park

វិទ្យាស្ថានសត្វស្លាបសាធារណរដ្ឋកូរ៉េ : Sun-Chang Song

Saemangeum Life-Peace Cheonbuk Union : Yong-ki Ju

សាកលវិទ្យាល័យជាតិសេអ៊ូលកូរ៉េ : Kyeong-Won Kim

អង្គការដីសើម និងសត្វស្លាបកូរ៉េ : Kyung-Cheol Kim

## ថ្ងៃទី១ : ថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១០

### របៀបវារៈ ១. សេចក្តីផ្តើម

### របៀបវារៈ ១.១ សន្ទរកថាបើកកម្មវិធីៈ ប្រទេសម្ចាស់ផ្ទះ និង ទីក្រុងដែលជាម្ចាស់ផ្ទះ

២. ប្រធានអង្គប្រជុំ Dr. Yeon-Man Jeong (ប្រធានទូទៅ ការិយាល័យអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន នៃសាធារណរដ្ឋកូរ៉េ) បានបើកអង្គប្រជុំ និងស្វាគមន៍ដល់គណៈប្រតិភូ ចំពោះការមកដល់កូរ៉េ។ លោកប្រធានបានបង្ហាញការព្រួយបារម្ភរបស់លោក ចំពោះការប្រែប្រួលអាកាសធាតុនិងការបាត់បង់ជីវៈចម្រុះ និងបានបង្ហាញអំពីសកម្មភាពជាក់ស្តែងរបស់ភាពជាដៃគូផ្លូវហោះហើរអូស្ត្រាលី–អាស៊ីខាងកើត EAAFP អាចជាដំណោះស្រាយ ចំពោះបញ្ហាទាំងនេះ។ លើសពីនេះ លោកបានលើកទឹកចិត្តដល់រដ្ឋាភិបាល និងអង្គការពាក់ព័ន្ធឱ្យចូលរួម ក្នុងសកម្មភាពទាំងនេះ។

៣. អភិបាលរងក្រុង (Incheon) ដែលជាម្ចាស់ផ្ទះនៃកិច្ចប្រជុំនេះ គឺ លោក Chang-Gu Lee បានថ្លែងសន្ទរកថាស្វាគមន៍ ដោយសម្តែងនូវអំណរគុណចំពោះអ្នកចូលរួម ហើយបានកត់សំគាល់ថា កិច្ចប្រជុំនេះនឹងអាចរួមចំណែកដោះស្រាយ ចំពោះបញ្ហាប្រែប្រួលអាកាសធាតុ ។ លោកបានសម្តែងនូវឆន្ទៈសហការយ៉ាងពេញលេញ ជាមួយនឹងភាគីដៃគូ និងគាំទ្រចំពោះសកម្មភាពទាំងឡាយនោះ។

### របៀបវារៈ១.២ ការតែងតាំងប្រធានអង្គប្រជុំ និងអ្នកតំណាង

៤. ប្រធានភាគីដៃគូបានសម្តែងនូវការអរគុណចំពោះអនុប្រធានភាគីដៃគូ គឺ លោក Zuiten Tsukamoto (ជប៉ុន) ដែលបានទទួលធ្វើ ជាប្រធាននៃកិច្ចប្រជុំលោកទី ៤ នេះ។

៥. ប្រធានភាគីដៃគូបានតែងតាំងអ្នកតំណាង Dr. Chang-Yong Choi and Ms. Aram Lee (លេខាធិការដ្ឋានដ្ឋាន EAAFP) និង លោក Suh Seung-Oh (មជ្ឈមណ្ឌលប្រចាំតំបន់រ៉ាមសារអាស៊ីខាងកើត RRCEA ) ។ លោក Maurice Lineman (RRCEA) ជំនួយការឱ្យលោក Suh ដោយមានការអនុម័ត យល់ព្រមពីប្រធានប្រតិបត្តិ EAAFP ។

៦. ថតរូបរួមគ្នាជាមួយភាគីដៃគូទាំងអស់ និងអ្នកចូលរួមផ្សេងៗទៀត ។

**របៀបវារៈ ១.៣ ការអនុម័តលើរបៀបវារៈបណ្តោះអាសន្ន សំរាប់កិច្ចប្រជុំភាគីដៃគូលើកទីបួន**

៧. ប្រធានប្រតិបត្តិបានបង្ហាញគណៈប្រតិភូអំពីឯកសាររបៀបវារៈដែលបានកែប្រែជាលើកទី៣ និងរបៀបវារៈ នៃកិច្ចប្រជុំនៅទីនេះ។ ភាគីដៃគូបានឯកភាពលើរបៀបវារៈនៃកិច្ចប្រជុំភាគីដៃគូលើកទី ៤ នេះ។

**របៀបវារៈ ១.៤ ស្វាគមន៍ចំពោះភាគីដៃគូ (សមាជិកចាស់ និងថ្មី)និងការអនុញ្ញាតឱ្យចូលនៃអ្នកសង្កេតការ**

៨. ប្រធានប្រតិបត្តិបានថ្លែងអំណរគុណចំពោះតំណាងភាគីដៃគូសំខាន់ៗ (១៦) ។ លោកបានលើកឡើងអំពីការសុំទោសពីដៃគូចំនួន ៥ ដែលមិនអាចចូលរួមក្នុងកិច្ចប្រជុំនេះ ហើយប្រាថ្នាចង់ចូលរួមក្នុងសកម្មភាព នៃភាពជាដៃគូនេះ នៅអនាគត ។

៩. ដោយអនុលោមតាមកថាខ័ណ្ឌទី ៨ នៃ ឯកសាភាពជាដៃគូ ដែលកត់សំគាល់ឃើញថា គ្មានការជំទាស់ណាមួយត្រូវបានលើកឡើង ក្នុងពេលវេលានេះឡើយ។ អង្គការ WWT (Wildfowl and Wetlands Trust) បានជម្រាបអង្គប្រជុំថាខ្លួន គឺ ជាដៃគូថ្មី ។ ប្រធានប្រតិបត្តិ បានស្វាគមន៍ ចំពោះលោកបណ្ឌិត Baz Hughes ដែលជាតំណាងអង្គការ WWT ក្នុងកិច្ចប្រជុំលើកទី ៤ នេះ ហើយបានឱ្យដឹងថា វិញ្ញាបនបត្របញ្ជាក់អំពីការចូលជាសមាជិកនេះ នឹងរៀបចំដោយលេខាធិការដ្ឋាន ហើយនឹងផ្តល់ជូន WWT នៅពេលឆាប់ៗ ។

១០. ប្រធានប្រតិបត្តិបានស្វាគមន៍ចំពោះភាគីដៃគូដែលមានសក្តានុពលរួមមានៈ ថៃ ម៉ាឡេស៊ី បង់ក្លាដែស (ដែលបានចូលរួមក្នុងកិច្ចប្រជុំដៃគូនេះ) និងមជ្ឈមណ្ឌលប្រចាំតំបន់រ៉ាមសារអាស៊ីខាងកើត ។ លោកក៏បានស្វាគមន៍ជាពិសេស ចំពោះអ្នកគាំទ្រភាពជាដៃគូនេះ ក្នុងប្រទេសដែលជាម្ចាស់ផ្ទះមានលោកសាស្ត្រាចារ្យ Woo-Shin Lee សាកលវិទ្យាល័យជាតិសេអ៊ូល Dr. Kyong-Hee Oh និង Dr. Jin-Han Kim វិទ្យាស្ថានជាតិធនធានជីវៈចម្រុះ នៃសាធារណៈរដ្ឋកូរ៉េ។

១១. បញ្ជីអវត្តមានត្រូវបានចែកជូនដល់អ្នកចូលរួមទាំងអស់ក្នុងពេលប្រជុំ ដែលមានអ្នកចូលរួមម្នាក់មកយឺត ហើយបានចុះឈ្មោះ។ មានអ្នកចូលរួមអន្តរជាតិចំនួន ៣១ នាក់ ក្នុងស្រុកចំនួន ៣៩ នាក់ (សរុប ៧០ នាក់) ព្រមទាំងបុគ្គលិកលេខាធិការដ្ឋាន ៧ នាក់ និងអ្នកស្ម័គ្រ ៦ នាក់ (ចំណាំ: ចំនួនអ្នកចូលរួមក្នុងស្រុកមិនច្បាស់លាស់)។

**របៀបវារៈ ១.៥ កំណត់ហេតុកិច្ចប្រជុំភាពជាដៃគូលើកទី ៣**

១២. របាយការណ៍ស្តីពីកិច្ចប្រជុំលើកទី ៣ ដែលបានធ្វើឡើង នៅថ្ងៃទី ៦-៧ ខែវិច្ឆិកា ឆ្នាំ ២០០៨ នៅ Incheon សាធារណរដ្ឋកូរ៉េ បានបង្ហោះលើគេហទំព័រ ក្នុងរយៈពេលយ៉ាងយូរ។ វាត្រូវបានទទួលស្គាល់ ដោយភាគីដៃគូថាជាការកត់ត្រាយ៉ាងត្រឹមត្រូវ ។

**របៀបវារៈ ២ ការពិនិត្យរបាយការណ៍**

**របៀបវារៈ ២១ ការពិនិត្យរបាយការណ៍ របាយការណ៍សង្ខេបពីលេខាធិការដ្ឋាន**

១៣. ប្រធានប្រតិបត្តិបានណែនាំខ្លួន បុគ្គលិកលេខាធិការដ្ឋានឱ្យភាគីដៃគូស្គាល់ រួមមានលោក: Mr. Eui-Yeon Lee (អនុប្រធាន) Mrs. Woo Mee-Hyang (មន្ត្រីរដ្ឋបាល)និង លោក Hyeong-Mun Kim (មន្ត្រីហិរញ្ញវត្ថុ) ដែលមកពីរដ្ឋាភិបាលក្រុង Incheon, Dr. Chang-Yong Choi (មន្ត្រីវិទ្យាសាស្ត្រ) Ms. Aram Lee (មន្ត្រីព័ត៌មាន និងទំនាក់ទំនង) និង Ms. Min-Seon Kim (មន្ត្រីផ្នែកបោះពុម្ព)។

១៤. ប្រធានប្រតិបត្តិ បានរៀបរាប់សង្ខេបអំពីប្រវត្តិនៃការបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៅប្រទេសកូរ៉េ និងសកម្មភាពរដ្ឋបាល ក្នុងឆ្នាំ ២០០៩ ។ លោកបានថ្លែងអំណរគុណដល់លេខាធិការដ្ឋានស្តីទី (Miki Koyama) ចំពោះការងាររបស់លោកស្រី ដែលបានធ្វើរហូតដល់ពាក់កណ្តាលឆ្នាំ ២០០៩ ដោយរួមបញ្ចូលទាំង ការគាំទ្របង្កើតអនុស្សារណៈយោគយល់គ្នា(MOU) ដើម្បីទទួលលេខាធិការដ្ឋាន ដោយប្រទេសកូរ៉េ ។ លោកក៏បានថ្លែងអំណរគុណផងដែរ ដល់បុគ្គលិកទី ២ ដែលបានបង្កើតការិយាល័យលេខាធិការដ្ឋាន នៅមុនពេល ការងាររបស់គាត់ចាប់ផ្តើម នៅខែ វិច្ឆិកា ឆ្នាំ ២០០៩ ។

១៥. លោកបានបង្ហាញតារាងរបាយការណ៍របស់សវនករ (BDO Daejoo LLC) កាលពីខែកក្កដា–ខែធ្នូ ឆ្នាំ ២០០៩ ដែលបានបង្ហាញអំពីការចំណាយប្រាក់សរុប ១៧៣ លាន KRW (វ៉ុន)។ ដោយសារតម្រូវការជាពិសេស របស់ម្ចាស់មូលនិធិ គណនេយ្យបានប្រតិបត្តិការលើទឹកប្រាក់មូលដ្ឋាន សំរាប់ឆ្នាំ ២០០៩ ។ មូលនិធិសរុបសម្រាប់ឆ្នាំ ២០១០នេះ បាននិងកំពុងផ្គត់ផ្គង់ ដោយរដ្ឋាភិបាលក្រុងអ៊ិនជីន (Incheon) ហើយ ជប៉ុនបានសន្យាផ្តល់មូលនិធិសម្រាប់ទ្រទ្រង់អ្នកចូលរួមដែលជាតំណាងមកពីប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងកិច្ចប្រជុំដៃគូលើកទី៤។

១៦. បញ្ហាផ្សេងៗដែលបានលើកឡើងក្នុងកិច្ចប្រជុំភាគីដៃគូលើកទី ៣ ត្រូវបានដោះស្រាយក្នុងឆ្នាំ២០០៩ ឬ នឹងលើកឡើងក្នុងរបៀបវារៈផ្សេងៗទៀត នៅក្នុងកិច្ចប្រជុំ នៅពេលនេះ។

១៧. ភាគីដៃគូទាំងអស់បានទទួលយល់ព្រមចំពោះរបាយការណ៍នេះ។

## របៀបវារៈ ២២ សេចក្តីសង្ខេបអំពីព័ត៌មានទាន់ហេតុការណ៍ពីក្រុមការងារ EAAFP

## របៀបវារៈ ២២១ ក្រុមការងារសត្វក្រៀល

១៨. អង្គការជីវិតសត្វស្លាបអន្តរជាតិ–អាស៊ី បានធ្វើបទបង្ហាញរបាយការណ៍របស់ក្រុម និងបានកត់សំគាល់ថា មានអ្នកចូលរួមចំណែកជាច្រើន ក៏ដូចជាទីប្រឹក្សារបស់ខ្លួន នៅក្នុងការងារក្រុមអស់រយៈពេលដ៏វែងកន្លងមក ។ បញ្ជីសមាជិកក្រុមប្រឹក្សាភិបាលគួរត្រូវតែបញ្ចប់ នៅ ២ ខែក្រោយ ។ យោងទៅលើការអនុម័ត នៃល័ក្ខខ័ណ្ឌការងាររបស់ក្រុមនេះ នៅឆ្នាំ២០០៨ ហើយក្រុមចង់បង្កើនឱកាសសម្រាប់សហប្រតិបត្តិការ ក្រោមភាពជាដៃគូ ។ ចាប់តាំងពីកិច្ចប្រជុំលើកទី ៣ ការប្រជុំក្រុមបានរៀបចំឡើង នៅហ្គូមុី (Gumi) ប្រទេសកូរ៉េ និងហារប៊ីន (Harbin) ប្រទេសចិន ហើយសកម្មភាពថ្មីៗ ត្រូវដាក់បញ្ចូលក្នុងគម្រោងអានប្យុង (Anbyon) ។

១៩. AWSG បានសួរថា តើអ្វី គឺជាប្រភពមូលនិធិ សំរាប់សកម្មភាពក្រុម ហើយអង្គការជីវិតសត្វស្លាបបានឆ្លើយថា ការផ្តល់មូលនិធិបានមកពីកម្មវិធីមូលនិធី JFGE ក្រសួងបរិស្ថាន ជប៉ុន អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដូចជា អង្គការមូលនិធិសត្វក្រៀលអន្តរជាតិ (ICF) អង្គការជាតិ និងរដ្ឋាភិបាល និងស្ថាប័នផ្សេងៗ ។ ការចូលរួមវិភាគទានខ្លះ គឺ ទឹកចិត្តប្រសើរជាង ប្រាក់ ។

## របៀបវារៈ ២២២ ក្រុមការងារសត្វស្លាបតំបន់ឆ្នេរ

២០. AWSG បានធ្វើបទបង្ហាញរបាយការណ៍របស់ក្រុម ហើយបានបញ្ជាក់ថា ក្រុមសង្ឃឹមថា រក្សាការយកចិត្តទុកដាក់លើគោលបំណងនៃភាគីដៃគូ ហើយសមាជិកជំនាញអាចផ្តល់ប្រឹក្សាបានដល់ភាគីដៃគូ ។ គេបានស្នើរឡើងថា ការពិភាក្សាបញ្ហាដែលបានលើកឡើង នៅក្នុងរបាយការណ៍នេះ គឺ យោងទៅលើការពិភាក្សាក្រុមតូច ក្នុងកំឡុងពេលកិច្ចប្រជុំ ហើយបន្ទាប់មក គឺ ការពិភាក្សាក្នុងចំណោមភាគីដៃគូទាំងអស់។ បញ្ហាទាំងនេះ ត្រូវដាក់បញ្ចូលទៅក្នុងការកំណត់តួនាទីរបស់ក្រុមការងារ ។

## របៀបវារៈ ២២៣ ក្រុមការងារ Anatidae

២១. ប្រធានក្រុម លោក Masayuki Kurechi (JAWGP) បានធ្វើបទបង្ហាញអំពីរបាយការណ៍ដូចក្នុងឯកសាររបៀបវារៈ។

## របៀបវារៈ ២២៤ ក្រុមការងារសត្វស្លាបសមុទ្រ

២២. ក្រុមនេះមិនមានតំណាងនៅក្នុងកិច្ចប្រជុំនេះទេ ។ សហរដ្ឋអាមេរិចបានប្រកាសម្តងទៀតថា លោក Kent Wohl អតីតប្រធានក្រុមការងារសត្វស្លាបសមុទ្រ ដែលជាសមាជិកនៃកម្មវិធីសត្វស្លាបទេសន្តរប្រវេសន៍ ដែលគ្មានការបរបាញ់កំសាន្ត នៃរដ្ឋាភិបាលសហរដ្ឋអាមេរិច ប៉ុន្តែគាត់បានចូលនិវត្តហើយ ។ ដូច្នេះ ក្រុមនេះ ហាក់ដូចជា គ្មានសកម្មភាពអ្វី ឡើយ ក្នុងកំឡុងពេលធ្វើរបាយការណ៍ ។

២៣. អង្គការជីវិតសត្វស្លាបអន្តរជាតិបានថ្លែងថា សត្វស្លាបសមុទ្រកំពុងទទួលរងការគំរាមកំហែងយ៉ាងខ្លាំង ហើយ អង្គការជីវិតសត្វស្លាបអន្តរជាតិមានការចាប់អារម្មណ៍យ៉ាងខ្លាំង ក្នុងការធ្វើឱ្យដូចដើមវិញចំពោះក្រុមការងារ សត្វស្លាបសមុទ្រ មុនកិច្ចប្រជុំភាគីដៃគូនៅពេលបន្ទាប់ និងធ្វើជាប្រធាន ប្រសិនបើចាំបាច់។ អង្គការនេះបាន ស្នើឱ្យមានការប្រជុំមួយថ្ងៃ មុនកិច្ចប្រជុំភាគីដៃគូលើកទី ៥ ដើម្បីរៀបចំក្រុមការងារសត្វស្លាបសមុទ្រឡើងវិញ ។ តាងនាមឱ្យភាគីដៃគូទាំងអស់ ប្រធានប្រតិបត្តិបានថ្លែងអំណរគុណដល់អង្គការជីវិតសត្វស្លាបអន្តរជាតិ។

## របៀបវារៈ ២២៥ ក្រុមការងារផ្តាសាយបក្សី

២៤. តំណាងលេខាធិការដ្ឋានតំបន់រ៉ាមសារ បានធ្វើបទបង្ហាញរបាយការណ៍ និងបានសុំអភ័យទោសពីអង្គការ FAO (Scott Newman) ដែលកំពុងស្វែងរកការបន្តកិច្ចសហការជាមួយនឹង EAAFP ។ ក្រុមនេះបានចាប់ផ្តើម នៅក្រោយឆ្នាំ ២០០៦ ដែលបានអនុវត្តសកម្មភាពសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ ដូចជា អង្គការ FAO ហើយសង្ឃឹមថា នឹងសហការជាមួយភាគីដៃគូជាច្រើនទៀត ។ ក្រុមនេះមិនបានប្រជុំនៅឆ្នាំ២០០៩ទេ ប៉ុន្តែបានបង្កើតប្រព័ន្ធតាមដានការធ្វើទេសន្តរប្រវេសន៍ និងផ្លូវរបស់សត្វស្លាបទឹក។ ព័ត៌មាននេះអាចរកបាន នៅលើ អ៊ិនធឺណេត ។

២៥. សហរដ្ឋអាមេរិចបានផ្តល់យោបល់ថា ទីភ្នាក់ងារសហរដ្ឋអាមេរិច (USGS, USFWS) បានអនុវត្តការសិក្សា តាមដាន តាមរយៈប្រព័ន្ធផ្កាយរណប ហើយសម្ភារៈពាក់ព័ន្ធការសិក្សានេះ អាចរកបានពី គេហទំព័រ USGS ។

## របៀបវារៈ ២២៦ របាយការណ៍អំពីសត្វក្រៀល

២៦. អង្គការមូលនិធិសត្វក្រៀលអន្តរជាតិ ICF និង អនុសញ្ញាប្រភេទធ្វើទេសន្តរប្រវេសន៍ AEWA បានបង្ហាញនូវ សកម្មភាពរបស់ ICF និង UNEP/GEF ស្តីអំពីផ្លូវហោះហើរ២ របស់សត្វក្រៀលនៅអាស៊ី និងធ្វើផែនការ សំរាប់បោះពុម្ពផ្សព្វផ្សាយ និងបន្តអនុវត្តគម្រោងដែលមានលក្ខណៈធំជាងនេះ។ គម្រោង Siberian Crane គឺជាគម្រោងដែលផ្តោតសំខាន់លើតំបន់ ប៉ុន្តែផ្តល់ប្រយោជន៍ ដល់ប្រភេទសត្វស្លាបទឹកជាច្រើន។

**របៀបវារៈ ៣ ឆ្ពោះទៅរកសកម្មភាពនៃភាពជាដៃគូផ្លូវហោះហើរ : សង្ខេបរបាយការណ៍ឆ្នាំ ២០០៩ និងផ្តោតលើផែនការ ឆ្នាំ ២០១០**

**របៀបវារៈ ៣.0 សង្ខេបរបាយការណ៍នៃភាគីដៃគូដែលបានផ្ញើជូនលេខាធិការដ្ឋានដ្ឋាន (ដោយប្រើទម្រង់គំរូ)**

២៧. ប្រធានប្រតិបត្តិបានពន្យល់បង្ហាញអំពីរបៀបប្រើប្រាស់ទម្រង់របាយការណ៍គំរូ ដើម្បីរាយការអំពីលទ្ធផល និងអាចប្រើប្រាស់លទ្ធផលទាំងអស់ដែលបានចងក្រងក្នុងទម្រង់កម្មវិធីអ៊ិចហ្សែល (Excel spreadsheet format) ។ របាយការណ៍ពីភាគីដៃគូចំនួន ៧ (៤ រដ្ឋាភិបាល និង ៣ អង្គការមិនមែនរដ្ឋាភិបាន) និងក្រុមការងារមួយបានទទួលរបាយការណ៍ទាន់ពេល ដើម្បីធ្វើការវិភាគ។ របាយការណ៍ផ្សេងទៀតដែលមកដល់យឺតយ៉ាវ វី មិនអាចដាក់ស្នើមកបាន ដោយសារផលវិបាកផ្នែកបច្ចេកទេស ។ ឆ្លើយតបនឹងរបាយការណ៍ដែលស្ថិតនៅក្រោម ១៤ លទ្ធផលនៃផែនការប្រតិបត្តិភាពជាដៃគូ ផ្តល់នូវគោលការណ៍ណែនាំ ដល់ភាពជាដៃគូស្តីពីប្រធានបទដែលជាអាទិភាព សំរាប់សហប្រតិបត្តិការភាគីដៃគូរួមមាន:

- ករណីសិក្សាលើការគ្រប់គ្រងការគំរាមកំហែង តំបន់បណ្តាញផ្លូវហោះហើរ
- កំណត់ចំណុចខ្វះចន្លោះក្នុងការយល់ដឹងដែលទាក់ទងនឹងតំបន់បណ្តាញផ្លូវហោះហើរ
- បង្កើតឱ្យមានកម្មវិធីគ្រប់គ្រងទីជម្រក
- បង្កើនការសហការជាអន្តរជាតិ រវាងអ្នកស្រាវជ្រាវ
- ការបង្កើតបណ្តាញកសាងសមត្ថភាពថ្នាក់ជាតិ

២៨. លេខាធិការដ្ឋាននឹងបញ្ចូលរបាយការណ៍ដែលផ្ញើមកយឺត ក្នុងការវិភាគ និងយកចិត្តទុកដាក់អំពីលទ្ធផល ក្នុងការពិនិត្យឡើងវិញ ផែនការសំរាប់ឆ្នាំ ២០១០។

**របៀបវារៈ ៣.១ គោលបំណង ១: បង្កើតបណ្តាញតំបន់ផ្លូវហោះហើរ**

**របៀបវារៈ ៣.១.១ ស្ថានភាពនៃបណ្តាញតំបន់ផ្លូវហោះហើរបច្ចុប្បន្ន និងការកំណត់នៅពេលថ្មីៗ ឬស្នើសុំ**

២៩. ប្រធានប្រតិបត្តិបានរំលឹកភាគីដៃគូថា បណ្តាញតំបន់ផ្លូវហោះហើរ គឺជាមូលដ្ឋានគ្រឹះនៃភាគីដៃគូ ហើយបានរាយការណ៍ថា មានតែមួយកន្លែងគត់ (Kejo-numa ប្រទេសជប៉ុន) ដែលបានបន្ថែមចូលទៅក្នុងបណ្តាញនេះ ចាប់តាំងពីកិច្ចប្រជុំលើកទី ៣ (សរុបតំបន់បច្ចុប្បន្នគឺមានចំនួន ៩៨)។ លោកបានប្រាប់ឱ្យដឹងថា ភាគីដៃគូ គួរតែតាមដានជាមួយលេខាធិការដ្ឋាន ដើម្បីធ្វើការផ្ទេរតំបន់ ពីបណ្តាញចាស់ទៅបណ្តាញថ្មី ដើម្បី

បង្កើនភាគរយនៃការទទួលស្គាល់តំបន់សំខាន់ៗ នៅក្នុងបណ្តាញនេះ និងកំណត់មធ្យោបាយ ដើម្បីបង្កើនទម្រង់នៃបណ្តាញនេះ។

៣០. អង្គការដីសើមអន្តរជាតិបានកត់សំគាល់ថា បណ្តាញនេះផ្តល់ការទំនាក់ទំនងទូទាំងផ្លូវហោះហើរ ហើយបានថ្លែងអំណរគុណដល់ដៃគូរដ្ឋាភិបាល ចំពោះការខិតខំប្រឹងប្រែងរបស់ពួកគេ និងលើកទឹកចិត្តឱ្យធ្វើវិនិយោគបន្ថែមទៀត ហើយបានសួរថា តើភាពជាដៃគូអាចជួយពួកគេបានយ៉ាងដូចម្តេច? ឧទាហរណ៍ៈ ដូចជាករណីសិក្សា ?

៣១. ប្រទេសឥណ្ឌូនេស៊ីបានឆ្លើយថា គេបានដឹងអំពីតំបន់បណ្តាញដែលមានសក្តានុពល ប៉ុន្តែ ខ្វះសមត្ថភាពក្នុងការតែងតាំងបញ្ចូលតំបន់នោះ។

៣២. ប្រទេសអូស្ត្រាលីបានផ្តល់យោបល់ថា ខ្លួនសង្ឃឹមថា ចំនួនបណ្តាញតំបន់នេះ នឹងកើនឡើង នៅឆ្នាំ ២០១០ និងមានការយកចិត្តទុកដាក់បំផុត ក្នុងការជួយភាគីដៃគូផ្សេងៗទៀត ប្រសិនបើត្រូវការ។

៣៣. កម្ពុជាបាននិយាយថា ដោយគោរពប្រធានដ្ឋាននានា ការបង្រួបបង្រួមស្ថាប័ន គឺ ជាការចាំបាច់ ដើម្បីធ្វើឱ្យបញ្ហាដែលមិនស៊ីសង្វាក់គ្នាឱ្យនៅកម្រិតទាបបំផុត ។ ការតែងតាំងតំបន់ គឺជាដំណើរការផ្លូវច្បាប់ដែលយឺតយ៉ាវមួយ ហើយ វាចាំបាច់ត្រូវមានការស្រាវជ្រាវបន្ថែម និងព័ត៌មានផ្សេងៗទៀត ដើម្បីជួយក្នុងការតែងតាំងតំបន់ ថ្មី ។

៣៤. រុស្ស៊ីបានសួរអំពីការផ្តល់យោបល់របស់លេខាធិការដ្ឋានថា តើគេអាចបំពេញតម្រូវការ នៃការផ្ទេរតំបន់មួយដោយរបៀបណា? អង្គការដីសើមអន្តរជាតិបានឆ្លើយថា តម្រូវអោយមានលិខិតពីទីភ្នាក់ងារសមស្របមួយទៅកាន់ភាពជាដៃគូ ។

៣៥. ជប៉ុនបានផ្តល់យោបល់ថា ប្រធានទ្រទ្រង់តំបន់ និងរដ្ឋាភិបាលតំបន់ គឺមានសារៈសំខាន់ ហើយថាសម្ភារៈសំរាប់ការអប់រំផ្សព្វផ្សាយ គឺ ចាំបាច់សំរាប់ការងារនេះ។

៣៦. សាធារណរដ្ឋកូរ៉េ បានប្រាប់អោយដឹងថា តំបន់សក្តានុពលថ្មីកំពុងធ្វើការវាយតម្លៃ ហើយបានផ្តល់យោបល់ថា ការអប់រំ ផ្សព្វផ្សាយសាធារណៈ និង គ្រឿងលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ គឺចាំបាច់ ដើម្បីបង្កើនការរៀបចំទីតាំងបណ្តាញការងារ។ កូរ៉េក៏បានអំពាវនាវផងដែរ អោយមានការសហការ រវាងរដ្ឋាភិបាលថ្នាក់កណ្តាល និងថ្នាក់ខេត្ត ដើម្បីធ្វើឱ្យប្រសើរឡើងនូវបណ្តាញនេះ។

៣៧. បង់ក្លាដែសបានលើកឡើងថា ខ្លួនមានតំបន់ដែលមានសក្តានុពលសំរាប់បណ្តាញទីតាំងផ្លូវហោះហើរ ហើយបានសួរប្រសិនបើលក្ខណៈវិនិច្ឆ័យរបស់រ៉ាមសារ សម្រាប់ការតែងតាំងតំបន់នឹងអាចអនុវត្តបាននៅក្នុងបណ្តាញនេះ

។ ផ្អែកលើលេខាធិការដ្ឋានដ្ឋានរ៉ាមសារ ប្រធានប្រតិបត្តិបានឆ្លើយតបថា ប្រសិនបើ តំបន់មួយបំពេញបាននូវលក្ខខ័ណ្ឌនិទ្ទិដ្ឋយទាក់ទាងនឹងសត្វស្លាបទឹករបស់រ៉ាមសារ ក្នុងករណីភាគច្រើន តំបន់នេះនឹងត្រូវបានទទួលស្គាល់ជាតំបន់បណ្ដាញនេះ ហើយបានបង្ហាញនូវឆន្ទះភាពជាភាគីដៃគូ ក្នុងការជួយបង់ក្លាដែស ។

៣៨. អង្គការដីសើមអន្តរជាតិបានរំលឹកដល់ភាគីដៃគូថា ការរៀបចំបណ្ដាញនេះមានបំណង ធ្វើឱ្យមានការងាយស្រួលជាងការរៀបចំតំបន់រ៉ាមសារ។ តំបន់រ៉ាមសារជាច្រើនគឺជាបេក្ខភាពដ៏ល្អសំរាប់បណ្ដាញតំបន់ផ្លូវហោះហើរនេះ ។ តំបន់សត្វស្លាបសំខាន់ៗខ្លះ ផ្ដល់ជាបេក្ខភាពផងដែរ ។ ប្រទេសរុស្ស៊ី និងចិន មានតំបន់ដែលមានសក្ដានុពល ប៉ុន្តែ វាមិនទាន់ច្បាស់នៅឡើយថាតើស្ថាប័នមួយណា គួរអនុម័តយល់ព្រមលើតំបន់ទាំងនោះ។

៣៩. ថៃបានសំណូមពរដល់លេខាធិការដ្ឋានអោយផ្ដល់គោលការណ៍ណែនាំ ស្ដីពីនិតិវិធីសំរាប់រៀបចំតំបន់បណ្ដាញនេះ ហើយបានកត់សម្គាល់ថា ការយល់ដឹងអំពីវិធីរៀបចំតំបន់ គឺជា ចំណុចសំខាន់ ។

**របៀបវារៈ ៣.១.២ ទម្រង់ការសំរាប់លេខាធិការដ្ឋានស្ដីពីដំណើរការ និងការធ្វើឱ្យមានការតែងតាំងតំបន់ថ្មី**

៤០. ទម្រង់ការបច្ចុប្បន្ន ត្រូវបានចែងនៅក្នុងឯកសារបៀបវារៈ ៣.១.២ ដែលត្រូវបានអនុម័ត ដោយភាគីដៃគូ ។

**របៀបវារៈ ៣.១.៣ កែលំអរភាពដែលអាចទទួលបានព័ត៌មានស្ដីពីតំបន់បណ្ដាញ**

៤១. ប្រធានប្រតិបត្តិបានរៀបរាប់អំពីទំហំនៃព័ត៌មានដែលអាចរកបានលើអ៊ិនធឺណេត (Online) សំរាប់តំបន់រ៉ាមសារ និងបានសុំឱ្យភាគីដៃគូទាំងអស់កំណត់ព័មានបណ្ដាញតំបន់ ដែលគួរធ្វើឱ្យអាចរកបានសម្រាប់ភាគីដៃគូ និងអ្នកផ្សេងទៀត នៅលើគេហទំព័ររបស់EAAFP ។

៤២. លេខាធិការដ្ឋានរ៉ាមសារ បានលើកទឹកចិត្តភាគីដៃគូឱ្យអនុវត្តភារកិច្ចរបស់ខ្លួន ហើយបានផ្ដល់អនុសាសន៍ ឱ្យប្រើប្រាស់ការធ្វើបទបង្ហាញភូមិសាស្ត្រ ហើយភ្ជាប់ជាមួយគេហទំព័រ (តំបន់រ៉ាមសារ និងតំបន់ផ្សេងទៀត) និងព័ត៌មានអំពីព្រឹត្តិការដែលនឹងកើតឡើង នាពេលខាងមុខ។ តំបន់បណ្ដាញជាច្រើនបានបង្ហាញលក្ខណៈពិសេសរបស់ខ្លួន នៅលើអ៊ិនធឺណេត (Internet) ដូចជាតំបន់រ៉ាមសារ។

៤៣. អនុសញ្ញាប្រភេទដែលធ្វើទេសន្តរប្រវេសន៍ គាំទ្រដោយប្រទេសជប៉ុន បានមានប្រសាសន៍ថា វាអាចជួយច្រើនសម្រាប់គំរូល្អដែលមានការប្រកួតប្រជែង ហើយលេខាធិការដ្ឋានរ៉ាមសារ បានផ្ដល់អនុសាសន៍លើគេហទំព័រ AEWA តំបន់សត្វស្លាបទឹកសំខាន់ៗ (ជីវិតសត្វស្លាប) និងការធ្វើជំរឿនសត្វស្លាបទឹកអាស៊ី (អង្គការដីសើមអន្តរជាតិ) ធ្វើជាគំរូ ។

៤៥. កូរ៉េ (NIBR) បានសំណូមពរឱ្យដាក់បញ្ចូល ក្រាហ្វិច ផែនទី និងរូបភាព ទេសភាព នៃតំបន់បណ្ដាញ ។

**របៀបវារៈ ៣.២ គោលបំណង ២: បង្កើនទំនាក់ទំនង ការអប់រំ និងផ្សព្វផ្សាយសាធារណៈ**

**របៀបវារៈ ៣.២១ ការបកប្រែឯកសារ ភាពជាដៃគូ: ស្ថានភាព និងការខ្វះចន្លោះ**

៤៦. ប្រធានប្រតិបត្តិបានផ្តល់ជូនឯកសារស្តីពីស្ថានភាពភាពជាដៃគូបច្ចុប្បន្ន ដែលបានបង្ហោះនៅលើគេហទំព័រ EAAFP ជាភាសារបស់ភាគីដៃគូទាំងនោះ ហើយបានស្នើឱ្យភាគីដៃគូកំណត់ចំណុចអាទិភាព សំរាប់លើកឡើងការខ្វះចន្លោះ។ គាត់បានកត់សម្គាល់ថា មានឯកសារជាច្រើនជាភាសាកូរ៉េ នឹងអាចរកបាននាពេលឆាប់ៗ ហើយបានថ្លែងអំណរគុណចំពោះ Dr. Kim Jin-han និងបានឱ្យដឹងថា លេខាធិការដ្ឋានមានថវិកា សំរាប់ការងារបកប្រែ ក្នុងឆ្នាំ ២០១០ នេះ ។

៤៧. ជប៉ុនបានផ្តល់យោបល់ថា ខ្លួនអាចផ្តល់ឯកសារជាច្រើនជាភាសាជប៉ុន

៤៨. អង្គការដីសើមអន្តរជាតិបានសុំស្នើថា រាល់ឯកសារសំខាន់ៗ ត្រូវបកប្រែជាភាសាដើមរបស់ភាគីដៃគូនីមួយៗ ឱ្យបានឆាប់តាមតែអាចធ្វើទៅបាន ។ ភាគីដៃគូខ្លួនឯង និងអង្គការក្រៅរដ្ឋាភិបាល អាចជួយលើការងារនេះ ដោយហេតុថាការជួយអ្នកជំនាញ គឺថ្លៃណាស់ ។ ភាគីដៃគូ គួរពិនិត្យ លើសេចក្តីព្រាងនេះ ។

**របៀបវារៈ ៣.២២ ការបង្កើតបន្ថែមគេហទំព័រភាគីដៃគូផ្លូវហោះហើរ www.eaaflyway.net**

៤៩. ប្រធានប្រតិបត្តិបានថ្លែងអំណរគុណ ដល់អ្នកដែលជួយបង្កើតគេហទំព័របច្ចុប្បន្ន ហើយបានកត់សម្គាល់ថា លក្ខណៈពិសេសជាច្រើនអាចពង្រីងបន្ថែម និងធ្វើឱ្យប្រសើរឡើង។ លោកបានស្នើថា កន្លែងរក្សាទិន្នន័យគេហទំព័របច្ចុប្បន្ន នៅ Melbourne IT (ប្រទេសអូស្ត្រាលី) បន្តរក្សានៅកន្លែងដដែលរហូតដល់ពាក់កណ្តាល ខែមិនា ឆ្នាំ២០១០ ។ មានសំណើរខ្លះអោយផ្ទេរកន្លែងរក្សាទិន្នន័យទៅប្រទេសកូរ៉េ ដែលចាំបាច់ត្រូវធ្វើការត្រួតពិនិត្យសម្ពភាពអ្នកប្រើប្រាស់ក្នុងប្រទេស ដែលទំហំទិន្នន័យសម្រាប់ប្រើប្រាស់ទាប (កូរ៉េមានប្រព័ន្ធ Internet ដែលមានល្បឿនលឿន) ដើម្បីបង្ហាញនូវលក្ខណៈពិសេស តម្រូវឱ្យសមត្ថភាព Internet មានកំរិតខ្ពស់ ។

៥០. AWSG បានសួថា តើភាគីដៃគូទាំងអស់អាចទៅកាន់តំបន់ដែលមាននាពេលបច្ចុប្បន្នដែរឬទេ ? ភាគីដៃគូទាំងអស់ បានឆ្លើយថា "បាន"។

៥១. ប្រទេសបង់ក្លាដែសបានផ្តល់អនុសាសន៍ថា ការចូលទស្សនាគេហទំព័រត្រូវបានគ្រប់គ្រង បន្ទាប់ពីមានការផ្លាស់ណាមួយត្រូវបានធ្វើឡើង។

**របៀបវារៈ ៣.២៣ សំណើឱ្យមានការធ្វើសិក្ខាសាលាជាសាកលស្តីអំពីផ្លូវហោះហើររបស់សត្វស្លាបទឹក**

៥២. លេខាធិការដ្ឋានរ៉ាមសារ បានយោងទៅលើផែនការដែលបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដោយរ៉ាមសារ CMS អង្គការដីសើមអន្តរជាតិ និងអង្គការផ្សេងៗទៀត សំរាប់សិក្ខាសាលាជាសាកលដែលអញ្ជើញអ្នកជំនាញដើម្បីចែករំលែកព័ត៌មាន និងបង្កើនកិច្ចសហប្រតិបត្តិការឱ្យកាន់តែប្រសើរជាង។ សិក្ខាសាលានេះបានយល់ព្រមដោយ STRP រ៉ាមសារ និង ក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃអនុសញ្ញាប្រភេទដែលធ្វើទេសន្តរប្រវេសន៍ ។ កំណត់កាលបរិច្ឆេទ នៅពាក់កណ្តាលចុងឆ្នាំ២០១០ ហើយសំណើឱ្យធ្វើនៅប្រទេសកូរ៉េ ដែលមានរយៈពេលបួនថ្ងៃ ដោយរាប់បញ្ចូលទាំងការចុះអង្កេតជាក់ស្តែងទៅទីវាល។

៥៣. ប្រធានប្រតិបត្តិបានបញ្ជាក់ថា លេខាធិការដ្ឋាន EAAFP រួមចំណែកលើការចំណាយ និងរៀបចំការចូលរួមដែលអាចឱ្យអ្នកជំនាញសំខាន់ៗបានចូលរួម ដែលនេះជាការលំបាកបំផុត ក្នុងការកំណត់កាលបរិច្ឆេទ ។

៥៤. រុស្ស៊ីបានស្នើឡើងថា សិក្ខាសាលានេះអាចធ្វើឡើង ដោយភ្ជាប់ជាមួយនឹងកិច្ចប្រជុំ លើកទី ៥ នៃភាគីដៃគូផ្លូវហោះហើរអូស្ត្រាលី– អាស៊ីខាងកើត ។

៥៥. សហរដ្ឋអាមេរិចបានស្នើឡើងថា ជម្រើស គឺដើម្បីឱ្យសិក្ខាសាលានេះផ្សារភ្ជាប់ជាមួយនឹងសន្និសិទសត្វស្លាបសមុទ្រអន្តរជាតិ ដែលត្រូវធ្វើនៅខែកញ្ញា ឆ្នាំ២០១០ នៅប្រទេសកាណាដា បើមិនដូច្នោះទេ ត្រូវពន្យាពេលរហូតដល់ឆ្នាំ ២០១១។

៥៦. អង្គការដីសើមអន្តរជាតិ និងលេខាធិការដ្ឋានរ៉ាមសារ បានប្រាប់ថា វានឹងមិនមែនជាសិក្ខាសាលាដ៏ធំនោះទេ អ្នកដែលត្រូវអញ្ជើញឱ្យចូលរួម ចំនួនប្រហែល ៣០នាក់ ដូច្នេះវាមិនមានភាពស្មុំគ្រាំក្នុងការរៀបចំឡើយ។

៥៧. មជ្ឈមណ្ឌលប្រចាំតំបន់រ៉ាមសារអាស៊ីខាងកើត RRCEA ដោយយោងលើគម្រោងប្រជុំ ៣ថ្ងៃ នៃកិច្ចប្រជុំបណ្តាញផ្សព្វផ្សាយ Changwon នៅប្រទេសកូរ៉េ នៅខែវិច្ឆិកា ឆ្នាំ២០១០ ហើយនឹងផ្តល់ឱ្យនូវ ការគាំទ្រផ្នែកហិរញ្ញវត្ថុ ការធ្វើសិក្ខាសាលាតូចៗ ប្រសិនបើ ធ្វើឡើងដោយភ្ជាប់ជាមួយនឹងព្រឹត្តិការណ៍ទាំងនោះ។

៥៨. លេខាធិការដ្ឋានដ្ឋានរ៉ាមសារបានអរគុណដល់ RRCEA ចំពោះការផ្តល់ឱ្យរបស់ខ្លួន ហើយបានស្នើឱ្យធ្វើការពិភាក្សាបន្ថែមទៀត និងផ្តល់ព័ត៌មានដល់ភាគីដៃគូទាំងអស់នូវផែនការច្បាស់លាស់ សំរាប់កំណត់កាលបរិច្ឆេទ ទីកន្លែង និងអ្នកដែលធ្វើជាម្ចាស់ផ្ទះ សំរាប់សិក្ខាសាលាផ្លូវហោះហើរសាកល ។

**របៀបវារៈ ៣.២៤ ព្រឹត្តិការ EAAFP ដែលបានស្នើឡើង នៅកិច្ចប្រជុំ CBD CoP10 ប្រទេសជប៉ុន**

៥៩. ជប៉ុនបានយោងលើសំណើរបស់ខ្លួន ដើម្បីរៀបចំព្រឹត្តិការស្តីពីភាពជាដៃគូ នៅពេល CoP10 នៃអនុសញ្ញាស្តីពីជីវៈចម្រុះ នៅទីក្រុងណាហ្គោយ៉ា ប្រទេសជប៉ុន ក្នុងឆ្នាំ ២០១០ ។ ដោយមានអ្នកចូលរួម និងអ្នកទស្សនា

១០.០០០ នាក់ ។ ការបង្ហាញនេះ គឺជាឱកាសមួយ សម្រាប់ផ្សព្វផ្សាយ EAAFP និងការងាររបស់ខ្លួនដែលមានប្រសិទ្ធភាពខ្ពស់ ។ ធនធានខ្លះដែលបានប្រើប្រាស់ស្រដៀងគ្នានឹងព្រឹត្តិការរ៉ាមសារ CoP10 អាចត្រូវរកបាន។

៦០. អង្គការដីសើមអន្តរជាតិបានអបអរសាទរ ដល់ប្រទេសជប៉ុនចំពោះគំនិតផ្តួចផ្តើមនេះ និងលើកទឹកចិត្តដៃគូឱ្យធ្វើទំនាក់ទំនងជាមួយនឹងស្ថាប័នពាក់ព័ន្ធ ដើម្បីធានាបញ្ហាសត្វស្លាបទឹកដែលធ្វើទេសន្តរប្រវេសន៍ ត្រូវបានគេលើកឡើង ក្នុងសម័យប្រជុំ CBD CoP10 ។ អង្គការនេះបានស្នើឱ្យលេខាធិការដ្ឋានធ្វើការសង្ខេបឱ្យភាគីដៃគូអំពីអ្វីដែលគេអាចផ្តល់វិភាគទានប្រសើរបំផុត ដល់CBD CoP10 ។

៦១. ប្រទេសបង់ក្លាដែសបានចោទសួរថា ប្រសិនបើ EAAFP អាចចូលរួម ក្នុង CBD CoP10 ។ លោកអនុប្រធានអង្គប្រជុំបានពន្យល់ថា ភាពជាដៃគូមិនមែនជាភាគី នៃ CBD ទេ ដូច្នេះមិនអាចចូលរួមក្នុងកិច្ចប្រជុំជាផ្លូវការបានឡើយ ប៉ុន្តែអាចចូលរួមក្នុងព្រឹត្តិការនានា ។ ប្រធានប្រតិបត្តិបានលើកទឹកចិត្តឱ្យប្រទេសបង់ក្លាដែសធ្វើទំនាក់ទំនងជាមួយជនបង្គោលរបស់ខ្លួនសម្រាប់ CBD ។

**របៀបវារៈ ៣.២៥ ការបកប្រែ និងផ្សព្វផ្សាយអត្ថបទវិទ្យាសាស្ត្រ និងឯកសារទាក់ទងផ្សេងៗ**

៦២. អូស្ត្រាលី បានយោងលើសំណើរបស់ខ្លួន ស្តីពីការបកប្រែ និងការផ្សព្វផ្សាយអត្ថបទវិទ្យាសាស្ត្រ និងអត្ថបទដែលទាក់ទងផ្សេងទៀត ដូចជា ការពិនិត្យឡើងវិញជាទៀងទាត់ របាយការណ៍ប្រចាំឆ្នាំ ដែលរាយការណ៍ដោយលេខាធិការដ្ឋាន EAAFP ។

៦៣. អង្គការដីសើមអន្តរជាតិបានយល់ព្រមចំពោះសំណើរនេះ ។

៦៤. ប្រធានប្រតិបត្តិបានថ្លែងអំណរគុណដល់ប្រទេសអូស្ត្រាលីចំពោះសំណើរនេះ និងការតាំងចិត្តអនុវត្តតាម ។

**របៀវវារៈ ៣.៣ គោលបំណង ៣: បង្កើនសកម្មភាពស្រាវជ្រាវផ្លូវហោះហើរ និងសកម្មភាពតាមដាន ការផ្លាស់ប្តូរព័ត៌មាន និងចំណេះដឹង**

**របៀបវារៈ ៣.៣.១ ការតាមដាន: ជំរឿនសត្វស្លាបទឹកអាស៊ី ការបង្ហាញនៃការពិនិត្យឡើងវិញរយះពេល ២០ ឆ្នាំ**

៦៥. អង្គការដីសើមអន្តរជាតិ បានផ្តល់ឯកសារដែលបោះផ្សាយអំពីស្ថានភាពសត្វស្លាបទឹកនៅអាស៊ី– លទ្ធផលនៃជំរឿនសត្វស្លាបទឹកអាស៊ី ១៩៨៧–២០០៧ ដល់ភាគីដៃគូទាំងអស់ និងអនុប្រធានអង្គប្រជុំ ។ ជំរឿននេះបានធ្វើនៅក្នុងប្រទេសចំនួន ២៧ និងមានជាង ៦៧០០កន្លែង ដែលក្នុងនោះមាន ៥០ តំបន់ដែលជាតំបន់បណ្តាញ EAAFP ។ ចំនួនសត្វស្លាបជាច្រើន គឺហាក់ដូចជាថយចុះ ចំណែកឯមួយចំនួនខ្លះទៀតថេរ ឬក៏កើនឡើងតិចតួច។ សៀវភៅនេះអាចទាញយកពីគេហទំព័រ របស់អង្គការដីសើមអន្តរជាតិ។

**របៀបវារៈ ៣.៣.២ ការតាមដានៈ សត្វស្លាបតំបន់ឆ្នេរ**

៦៦. AWSG បានរាយការណ៍អំពីការស្រាវជ្រាវសត្វស្លាបតំបន់ឆ្នេរ និងការតាមដានក្នុងតំបន់អាស៊ី-អូស្ត្រាលី និងបានបង្ហាញអំពីកម្មវិធីសត្វស្លាបតំបន់ឆ្នេរឆ្នាំ ២០២០ និងកម្មវិធី MYSMA (ការតាមដានទេសន្តរប្រវេសន៍នៅសមុទ្រលឿងក្នុងប្រទេសអូស្ត្រាលី) ដែលមានបំណង ដើម្បីបង្កើតនិន្នាការទំហំចំនួនសត្វស្លាបតំបន់ឆ្នេរ ហើយ ប្រសិនបើអាចនឹងត្រូវកំណត់មូលហេតុនៃការថយចុះចំនួននេះ។ លទ្ធផលដំបូងបង្ហាញថា ចំនួនសត្វស្លាបតំបន់ឆ្នេរមានការថយចុះស្ទើរគ្រប់ប្រភេទ ។ ការសិក្សាអំពីទីតាំងភូមិសាស្ត្រ អាចបង្កើនចំណេះដឹងច្រើន អំពីផ្លូវធ្វើទេសន្តរប្រវេសន៍ ។ AWSG គឺ ចង់ចែករំលែកបទពិសោធន៍ និងជំនាញរបស់អូស្ត្រាលី ជាមួយនឹងភាគីដៃគូ។

**របៀបវារៈ ៣.៣.៣ ការតាមដាន : ការតាមដានតំបន់ ១.០០០ (នៅជប៉ុន)**

៦៧. ជប៉ុនបានរាយការណ៍ពីសកម្មភាព និងលទ្ធផលពីកម្មវិធីតាមដានតំបន់ ១.០០០ នៅជប៉ុន។ គេបានរកឃើញថាមានការកើនឡើងចំនួនប្រភេទ ទា និង ក្ងាន។

**របៀបវារៈ ៣.៣.៤ ការតាមដាន : ការតាមដានលក្ខណៈតំបន់-ទីជម្រក ដែលបានស្នើឡើង**

៦៨. អង្គការជីវសើមអន្តរជាតិបានលើកឡើងថា ឯកសាររបៀបវារៈ អំពីសំណើឱ្យមានសិក្ខាសាលាបច្ចេកទេស (អាចដំណើរការបាននៅក្នុងខែឧសភា រឺ ខែមិថុនា ឆ្នាំ ២០១០) ដើម្បីបង្កើតឧបករណ៍គាំទ្រសេចក្តីសំរេចចិត្ត (DST) ដែលត្រូវពង្រឹងការតាមដានសត្វស្លាបទឹក និងទីជម្រករបស់វា នៅកម្រិតជាតិ និងកម្រិតផ្លូវហោះហើរជាសកល។ សិក្ខាសាលាតូចៗនឹងធ្វើឡើង ដើម្បីបង្កើតគោលការណ៍ និងយន្តការសំរាប់ការរៀបចំឧបករណ៍គាំទ្រសេចក្តីសំរេចចិត្ត (DST) ។

៦៩. ប្រធានប្រតិបត្តិបានផ្តល់យោបល់ថា លេខាធិការដ្ឋានដ្ឋានមានសមត្ថភាពក្នុងការរៀបចំសិក្ខាសាលាបែបនេះ ហើយ ដើរតួនាទីសមស្រប ក្នុងការសម្របសម្រួល និងគាំទ្រសកម្មភាពអង្កេត តាមដានក្នុងកម្រិតផ្លូវហោះហើរ។

៧០. អង្គការសត្វស្លាបអន្តរជាតិ (Birdlife International) និងអង្គការមូលនិធិសត្វក្រៀលពិភពលោក (ICF) បានលើកទឹកចិត្តឱ្យផ្សារភ្ជាប់ ឬដាក់បញ្ចូលគ្នាជាមួយនឹងតំបន់សត្វស្លាបសំខាន់ៗ (IBA) ក្នុងកម្មវិធីតាមដានជាតិ និងកម្មវិធីផ្សេងៗទៀត ដើម្បីបង្កើនការប្រើប្រាស់ធនធានទូទៅ និងការចែករំលែកទិន្នន័យ។

៧១. អង្គការដីសើមអន្តរជាតិ ដោយឆ្លើយតបទៅប្រទេសរុស្ស៊ី និងអូស្ត្រាលី ដែលបានផ្តល់យោបល់ថា ប្រភេទនៃឧបករណ៍ដែលគាំទ្រដល់ការសំរេចចិត្តអាចផ្សារភ្ជាប់ជាមួយទិន្នន័យសំខាន់ៗទាំងអស់ ដែលទាក់ទងនឹងប្រភេទ និងតំបន់ ហើយតាមរយៈនេះ ជួយដល់អ្នកធ្វើសេចក្តីសំរេចចិត្ត ។ គំរូមាននៅគ្រប់ទីកន្លែងទាំងអស់ (ឧទាហរណ៍គម្រោង WoW) ហើយបាននិងកំពុងធ្វើការពិភាក្សា នៅក្នុងកិច្ចប្រជុំភាគីដៃគូមុនៗ។ ភាគីដៃគូជួយក្នុងការចំណាយលើថ្លៃចូលរួមសំរាប់សិក្ខាសាលាតូចៗ។

៧២. ក្រុមប្រតិបត្តិត្រូវបានបង្កើតឡើង ដើម្បីស្វែងរកសំណើរថែមទៀត សំរាប់ការពិភាក្សាជាក្រុមតូចៗ ក្នុងកិច្ចប្រជុំលើកទី៤: អង្គការដីសើមអន្តរជាតិ (Doug Watkins), AWSG (Ken Gosbell), អង្គការមូលនិធិសត្វក្រៀលអន្តរជាតិ (Jim Harris), WWT (Baz Hughes), មូលនិធិសត្វព្រៃពិភពលោក (Bena Smith), Birdlife (Simba Chan), ឥណ្ឌូនេស៊ី (Agus), Ramsa (Taej Mundkur) និងអ្នកអង្កេតការពីប្រទេសបង់ក្លាដែស (Tapon Dey) និងអង្គការសត្វស្លាបកូរ៉េ (Nial Moores) បានយល់ព្រមចូលរួម។ គោលបំណងនៃគំនិតផ្តួចផ្តើមនេះ មានដូចជា: ដើម្បីធ្វើឱ្យសកម្មភាពដែលមានស្រាប់ប្រសើរឡើង ។ ដើម្បីផ្តល់ព័ត៌មានសំរាប់ការគ្រប់គ្រងសត្វស្លាបទឹក និងតំបន់សំខាន់ៗ ។ ដើម្បីពិនិត្យឡើងវិញ និងកែលំអរ ការតាមដានសត្វស្លាបទឹក ។ ដើម្បីបង្កើនសមត្ថភាព ។ ដើម្បីធ្វើឱ្យប្រសើរឡើងការតាមដានដែលទាក់ទងនឹង ជំងឺផ្តាសាយបក្សី និងការធ្វើឱ្យប្រសើរឡើងនូវការផ្តល់មូលនិធិ ។ ការចែករំលែកទិន្នន័យដែលល្អជាង គឺ មានប្រយោជន៍សំរាប់អ្នកដែលអាចរៀបចំទុកមុន ។ កិច្ចប្រជុំនេះនឹងមានអញ្ជើញអ្នកចូលរួមរហូតដល់ ១០នាក់ បើតាមការគ្រោង ហើយអ្នកចូលរួមខ្លះប្រហែលត្រូវផ្គត់ផ្គង់ការចំណាយដោយខ្លួន។

៧៣. អង្គការដីសើមអន្តរជាតិ អង្គការជីវិតសត្វស្លាបអន្តរជាតិ និង AWSG បានប្រឹងប្រែងបង្កើតឱ្យមានសិក្ខាសាលា និង សកម្មភាពបន្តបន្ទាប់។

**របៀបវារៈ ៣.៣.៥ ការតាមដាន : គំនិតផ្តួចផ្តើមធ្វើសារពើភ័ណ្ឌជីវៈចម្រុះនៅអាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍**

៧៤. ជប៉ុនបានផ្តល់ព័ត៌មានដល់ភាគីដៃគូទាំងអស់អំពី គំនិតផ្តួចផ្តើមឱ្យមានព័ត៌មានស្តីពីជីវៈចម្រុះ នៅតំបន់អាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ ដែលវានឹងធ្វើឡើង និងភ្ជាប់ជាមួយនឹង CBD CoP10 ។

៧៥. សាធារណៈរដ្ឋកូរ៉េបានបង្ហាញនូវចំណាប់អារម្មណ៍ចំពោះគំនិតផ្តួចផ្តើមនេះ ហើយបានសួរអំពីលក្ខណៈផ្សេងគ្នារវាងប្រព័ន្ធព័ត៌មានជីវៈចម្រុះ (BIS) និង Clearing House Mechanism (CHM) ដែលជប៉ុន និងថៃបានធ្វើការពន្យល់បញ្ជាក់ ។

៧៦. អង្គការដីសើមអន្តរជាតិ បានសួរថាតើត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីឱ្យទិន្នន័យទាំងអស់ដែលមានមានទំនាក់ទំនងជាមួយនឹងគំនិតផ្តួចផ្តើមនេះមិនជាន់គ្នា ហើយជប៉ុនបានធានាថា បញ្ហានេះនឹងត្រូវលើកយកមកពិភាក្សា។

៧៧. អូស្ត្រាលី បានលើកឡើង ឯកសាររបៀបវារៈរបស់ខ្លួន និង បានបញ្ជាក់លើតម្រូវការឱ្យធ្វើការពិនិត្យឡើងវិញនូវព័ត៌មានរបស់ផ្លូវហោះហើរ និងលើកឡើងអំពីបញ្ហា ដូចជា បាត់របទង់ជ័យ និងព័ត៌មានជាន់គ្នា។ អូស្ត្រាលីបានស្នើ ឱ្យមានក្រុមការងារ ដើម្បីកែលំអរបញ្ហាទាំងនេះ និងធ្វើការបង្កើតនូវការសម្របសម្រួល រយៈពេលវែង ដើម្បីបង្កើតឱ្យមានផ្លូវហោះហើរគ្រប់ទីកន្លែង ហើយអូស្ត្រាលីបានផ្តល់ជំនួយការម្នាក់នៃបុគ្គលិកភ្នាក់ងារនេះ។

៧៨. AWSG បានផ្តល់អនុសាសន៍ថា សត្វស្លាបតំបន់ឆ្នេរមានគោលការណ៍ដៅសំគាល់ ទោះបីជា ការប្រើប្រាស់នៃស្លាកពណ៌លើសត្វកើនឡើង ដែលនាំឱ្យមានការលំបាកក្នុងការស្វែងរកទង់ជ័យពណ៌ ម្យ៉ាងវិញទៀត គោលការណ៍ណែនាំនេះអាចមាន ឬមិនអាចមានសំរាប់ក្រុមសត្វស្លាបទឹកផ្សេងៗទៀត ។ អង្គការនេះបានបន្ថែមទៀតថា សក្តានុពលសំរាប់រាយការណ៍ នូវការរកឃើញទង់សំគាល់នៅអាស៊ី គឺច្រើនណាស់ ។ ដូចនេះការអប់រំ និងផ្សព្វផ្សាយស្តីពីទង់សំគាល់ និងការរាយការណ៍គឺជាការចាំបាច់ ។

៧៩. បង់ក្លាដែស បានសួរព័ត៌មានផ្សេងៗស្តីពីគោលការណ៍ណែនាំ ក្នុងការបំពាក់ពណ៌លើសត្វ ហើយអូស្ត្រាលីបានផ្តល់ដល់បង់ក្លាដែសនូវព័ត៌មាន ស្តីពីគោលការណ៍ណែនាំសំរាប់សត្វស្លាបតំបន់ឆ្នេរ។

៨០. អង្គការដីសើមអន្តរជាតិបានគូសបញ្ជាក់ថា គោលការណ៍ណែនាំបច្ចុប្បន្ន ព័ត៌មានទំនាក់ទំនង និងទិន្នន័យផ្សេងៗទៀត ស្តីពីសត្វស្លាបទឹកនៅអាស៊ីអាចរកបាននៅលើគេហទំព័រ របស់អង្គការដីសើមអន្តរជាតិ ។ នេះគឺជាធនធានដែលគ្មានយន្តការគ្រប់គ្រង ។ បទពិសោធន៍នៅតំបន់ AEWA អាចធ្វើជាគំរូ។ អង្គការនេះបានយល់ព្រមផងដែរថា ការដាក់សញ្ញាសំគាល់លើសត្វ គឺចាំបាច់សំរាប់តាមដានសត្វស្លាបតំបន់ឆ្នេរ ហើយគោលការណ៍ណែនាំ ដែលមានអាយុ២០ឆ្នាំ ចាំបាច់ត្រូវធ្វើឱ្យថ្មីឡើងវិញ ឱ្យសមស្របតាមបច្ចេកវិទ្យាថ្មីៗ ដែលត្រូវបានគេយកមកពិចារណា ។ អង្គការដីសើមអន្តរជាតិបានប្រើប្រព័ន្ធអ៊ីនធឺណេត ដែលមិនប្រើខ្សែ ដើម្បីបង្ហាញដល់ភាគីដៃគូទាំងអស់ នូវគេហទំព័ររបស់ខ្លួន ស្តីអំពីការបំពាក់ស្លាកលើសត្វស្លាបទឹក ដែលជាវិធីសំរាប់សិក្សាលើប្រភេទដែលធ្វើទេសន្តរប្រវេសន៍ និងព័ត៌មានដែលទំនាក់ទំនង ។

៨១. សមាគមជប៉ុនសំរាប់អភិរក្សក្ងានព្រៃ JAWGP (M. Kurechi, Anatidae WG) បានផ្តល់យោបល់ថាពណ៌ដែលអាចរកបាន គឺមានចំនួនកំណត់សំរាប់ពពួកក្ងាន ហើយពណ៌ដូចៗគ្នា គឺតែងតែត្រូវបានគេប្រើនៅតំបន់ផ្សេងៗគ្នាជាច្រើន ។ តំបន់ធំៗជាច្រើនដែលសត្វស្លាបទឹករស់នៅ គឺពិបាកក្នុងការតាមដានការផ្លាស់ទីរបស់វា ។

៨២. អង្គការជីវិតសត្វស្លាបអន្តរជាតិបានថ្លែងថា សត្វក្រៀល គឺចាំបាច់ត្រូវការធ្វើការទំនាក់ទំនងគ្នា និងកំណត់យកមតិទូទៅ សំរាប់គ្រោងការណ៍នៃការដាក់ស្លាក ។ អង្គការនេះបានផ្តល់អនុសាសន៍ដល់លេខាធិការដ្ឋាន ឱ្យដើរតួសំខាន់ក្នុងការទំនាក់ទំនងនេះ ហើយសង្ឃឹមថា បញ្ហានៃការដាក់ស្លាកអាចដោះស្រាយយ៉ាងឆាប់បំផុត ដែលផ្តល់ប្រវត្តិដ៏យូរអង្វែងនៃការពិភាក្សា។

៨៣. សាធារណៈរដ្ឋកូរ៉េបានរួមចំណែកថា ទោះបីជាមានគោលការណ៍ណែនាំ នៃការដាក់សញ្ញាលើក្រុមសត្វខ្លះយ៉ាងណាក៏ដោយ គឺ នៅតែមានការភ័ណ្ឌច្រឡំ ពីព្រោះការស្រាវជ្រាវជាច្រើនជាប់ពាក់ព័ន្ធនឹងមានការចែករំលែកពត៌មាន ក្នុងចំណោមអ្នកស្រាវជ្រាវ គឺជាការសំខាន់ណាស់ ។

៨៤. ប្រធានប្រតិបត្តិបានសន្និដ្ឋានថា ជាទស្សនៈនៃផលប្រយោជន៍កម្រិតអប្បបរមា ក្រុមការងារនឹងបង្កើតឡើងដើម្បីធ្វើឱ្យប្រសើរឡើង នូវកម្មវត្ថុនៃកិច្ចប្រជុំជាក្រុមតូច នៅក្នុងកិច្ចប្រជុំភាគីដៃគូលើកទី៤ និងធ្វើការកំណត់ផ្លូវដែលត្រូវឆ្ពោះទៅមុខ។

៨៥. អូស្ត្រាលីបានរាយការណ៍ជូនសម័យប្រជុំពេញអង្គថា ការងារទូទៅត្រូវបានទំនាក់ទំនង និងសម្របសម្រួល។ ការបង្កើតអ៊ីមែល ស្តីពីការដាក់ស្លាក ត្រូវបានផ្តល់អនុសាសន៍ ។ ការវិវឌ្ឍនៃវិទ្យាសាស្ត្រ ក្នុងការដាក់ស្លាកសំគាល់សត្វ សំរាប់ក្រុមសត្វស្លាបទឹកនីមួយៗ គួរត្រូវបោះពុម្ពផ្សព្វផ្សាយ ជាទូទៅ ។

៨៦. អូស្ត្រាលីសន្យានឹងរៀបចំអត្ថបទ សំរាប់កិច្ចប្រជុំភាគីដៃគូលើកទី ៥ ស្តីពីបញ្ហាសម្របសម្រួល និងជម្រើស។

៨៧. បង់ក្លាដែសបានស្នើរសុំអ្នកដឹកនាំគម្រោងតាមដានសកម្មភាពតាមរយៈផ្កាយរណប ឱ្យផ្តល់ពត៌មានដល់ប្រទេសដែលអាចទាក់ទងបាន អំពីពេលវេលាដែលសត្វស្លាបមានវត្តមាននៅក្នុងប្រទេសទាំងនោះ ។

៨៨. ឥណ្ឌូនេស៊ី បានស្នើឱ្យមានទំនាក់ទំនងកាន់តែខ្លាំងឡើង រវាងអ្នកគ្រប់គ្រងតំបន់នីមួយៗ។

៨៩. អង្គការដីសើមអន្តរជាតិបានផ្តល់អនុសាសន៍ លើការរៀបចំ សំយោគនៃយុទ្ធសាស្ត្រនៃការធ្វើទេសន្តរប្រវេសន៍របស់ប្រភេទដែលជ្រើសរើស និងវិធីសាស្ត្រសំរាប់តាមដាន ។ អូស្ត្រាលីបានយល់ព្រមថា នេះនឹងជួយដល់រដ្ឋាភិបាល ដើម្បីលៃលំរុងមូលនិធិ សម្រាប់បំពេញចំណុចខ្វះចន្លោះនៃចំណេះដឹង។ កូរ៉េបានបញ្ជាក់ថា ខ្លួនគាំទ្រគំនិតនេះ។

៩០. លេខាធិការដ្ឋាន អាចទាក់ទងជាមួយនឹងអង្គការដីសើមអន្តរជាតិ (ដែលមាននៅក្នុងបញ្ជីទំនាក់ទំនងលើអ៊ិនធឺណេត) ដើម្បីធ្វើបច្ចុប្បន្នភាពលំអិតអំពីមន្ត្រីដែលត្រូវធ្វើទំនាក់ទំនង សំរាប់គម្រោងការដាក់ស្លាក ឬការដៅសម្គាល់។

៩១. ប្រធានប្រតិបត្តិបានបញ្ជាក់ថា លេខាធិការដ្ឋាននឹងទទួលយកនូវរាល់ការផ្តល់អនុសាសន៍របស់ក្រុមការងារ។

**របៀបវារៈ ៣.៣.៧ ការប្រើប្រាស់ទម្រង់របាយការណ៍ វិធីដើម្បីទទួលបានលទ្ធផលល្អបំផុត**

៩២. ប្រធានប្រតិបត្តិបានពន្យល់អំពីវិធីដែលភាគីដៃគូអាចប្រើទម្រង់របាយការណ៍ប្រកបដោយប្រសិទ្ធភាព ហើយកត់សំគាល់ ថាភាគីដៃគូខ្លះបានជួបប្រទះបទពិសោធន៍លំបាក។

៩៣. អង្គការ WWT បានកត់សំគាល់ថា សំណួរខ្លះមានលក្ខណៈទូទៅបំផុត ហើយជាសំណួរបើក ហើយខ្លះទៀតភាគច្រើនផ្តោតលើរដ្ឋាភិបាល ជាងអង្គការមិនមែនរដ្ឋាភិបាល។

៩៤. អូស្ត្រាលីបានផ្តល់ប្រឹក្សាថា ការប្រើប្រាស់សុំណុំឯកសារ (.exe file) (ដូចជាទម្រង់របាយការណ៍) ទោះបីជាដាក់ក្នុងទម្រង់ឯកតូច (Zip files) អាចត្រូវធ្វើឱ្យគាំង ដោយប្រព័ន្ធភ្នាក់ងារសន្តិសុខ។ តើអាចបង្កើតប្រព័ន្ធទិន្នន័យតាមគេហទំព័របានដែរឬទេ ?

៩៥. ហ្វ្រីលីពីន បានផ្តល់ប្រឹក្សាថា វាអាចមានប្រយោជន៍ ក្នុងការផ្តល់អនុសាសន៍បន្ថែម នៅពេលដែល “ទេ” គឺជាចម្លើយ ដោយមិនមែនតែ នៅពេលដែល “បាទ” គឺជាចម្លើយនោះទេ ។

៩៦. អង្គការដីសើមអន្តរជាតិ និងអង្គការរ៉ាមសារ បានស្នើថា លទ្ធផលដែលអាចបោះពុម្ពបាន ដែលមានសំណួរ និងចម្លើយទាំងអស់នោះ គឺត្រូវការសម្រាប់ទស្សនៈទូទៅ ជាពិសេស លំដាប់ថ្នាក់នៃភ្នាក់ងាររដ្ឋាភិបាល។

៩៧. អូស្ត្រាលីបានផ្តល់ប្រឹក្សាដល់លេខាធិការដ្ឋាន អំពីឧបករណ៍ដែលអាចរកបាន ប្រសិនបើត្រូវការ។

**របៀបវារៈ ៣.៤ គោលបំណង ៤: ការកសាងសមត្ថភាព ដើម្បីគ្រប់គ្រងសត្វស្លាបទឹក និងទីជម្រករបស់វា**

**របៀបវារៈ ៣.៤.១ សិក្ខាសាលាស្តីពីភាគីដៃគូថ្នាក់ជាតិ– ភូមា ថៃ**

៩៨. អង្គការដីសើមអន្តរជាតិ បានទាញការយកចិត្តទុកដាក់ ចំពោះការងាររបស់ខ្លួន ចាប់តាំងពីកិច្ចប្រជុំភាគីដៃគូលើកទី៣ ក្នុងការសម្របសម្រួលសិក្ខាសាលា នៅប្រទេសថៃ និងភូមា ស្តីពីការបង្កើតភាគីដៃគូថ្នាក់ជាតិ ដើម្បីគាំទ្រភាពជាដៃគូផ្លូវហោះហើរនៅមូលដ្ឋាន ។ ភាពជាដៃគូថ្នាក់ជាតិរឹងមាំគួរពង្រឹងសមត្ថភាព សំរាប់ប្រទេសដើម្បីក្លាយជាភាគីដៃគូ នៃ EAAFP ។ នៅក្នុងប្រទេសខ្លះ ការផ្សារភ្ជាប់ នៃការអភិរក្សតំបន់ដីសើម និងសត្វស្លាបទឹក ដើម្បីកាត់បន្ថយភាពក្រីក្រ គឺចំណុចដែលគេចង់បាន។

៩៩. BANCA (អ្នកអង្កេតការ ភូមា) និងប្រទេសបង់ក្លាដែស បានផ្តល់អនុសាសន៍ថា ស្ថានភាពសត្វស្លាបជាច្រើននៅក្នុងប្រទេសរបស់ពួកគេ គឺទទួលរងគ្រោះថ្នាក់បំផុត ហើយការគាំទ្រអន្តរជាតិ គឺត្រូវការចាំបាច់បំផុត ដើម្បីបង្កើនសមត្ថភាពក្នុងប្រទេស សំរាប់ការគ្រប់គ្រង និងស្រាវជ្រាវ។

១០០. អង្គការសត្វស្លាបអន្តរជាតិ បានជំរុញឱ្យភាគីដៃគូបន្តការយកចិត្តដាក់ ។ ជប៉ុនបានផ្តល់មូលនិធិឱ្យគម្រោងសត្វស្លាបទឹក នៅប្រទេសភូមាមួយចំនួន ហើយអង្គការជីវិតសត្វស្លាប នឹងលើកទឹកចិត្តប្រទេសភូមាឱ្យចូលជាភាគីដៃគូ EAAFP ។

១០១. ប្រទេសបង់ក្លាដែស បានចាប់ផ្តើមក្លាយខ្លួនជាភាគីដៃគូ ។

១០២. ប្រធានប្រតិបត្តិ បានផ្តល់អនុសាសន៍ថា លេខាធិការដ្ឋាននឹងតាមដានជាមួយភាគីដៃគូដែលមានសក្តានុពល ។

**របៀបវារៈ ៣.៤២ សម្របសម្រួលការបង្កើត និងសកម្មភាពរបស់ភាពជាដៃគូជាតិ**

១០៣. ប្រធានប្រតិបត្តិបានផ្តល់អនុសាសន៍ដល់បណ្តាញ ឬ ភាពជាដៃគូជាតិ ដែលមានស្រាប់ សំរាប់សត្វស្លាបទឹក និងទីតាំងបណ្តាញផ្លូវហោះហើរ នៅប្រទេសជប៉ុន និកូរ៉េ ជាឧទាហរណ៍សំរាប់ការប្រលងប្រណាំង ។

១០៤. លេខាធិការដ្ឋានតំបន់រ៉ាមសារបានរំលឹកភាគីដៃគូថា គណៈកម្មាធិការរ៉ាមសារមាននៅក្នុងប្រទេសជាច្រើន ហើយអាចសម្របសម្រួល កិច្ចសហការក្នុងស្រុក អំពីបញ្ហាផ្លូវហោះហើរនេះ ហើយភាពជាដៃគូដ៏រឹងមាំគឺចាំបាច់ផងដែរ នៅតាមតំបន់ដែលមានសារៈសំខាន់នីមួយៗ ។

**របៀបវារៈ ៣.៥ គោលបំណង ៥: បង្កើតវិធីផ្លូវហោះហើរយ៉ាងទូលាយ ដើម្បីពង្រឹងស្ថានភាពអភិរក្ស នៃសត្វស្លាបទឹកដែលធ្វើទេសន្តរប្រវេសន៍**

**របៀបវារៈ ៣.៥.១ សហប្រតិបត្តិការតំបន់អេកូ-សមុទ្រលឿង**

១០៥. អង្គការដីសើមអន្តរជាតិ បានទាញការយកចិត្តទុកដាក់របស់ភាគីដៃគូ លើរបាយការណ៍របស់ខ្លួន ស្តីពីគម្រោងសហប្រតិបត្តិការតំបន់អេកូ-សមុទ្រលឿង នៅក្នុងឯកសាររបៀបវារៈ ។ គម្រោងនេះបានផ្តល់មូលនិធិ ដោយប្រទេសអូស្រ្តាលី និងអនុវត្តដោយអង្គការដីសើមអន្តរជាតិ (WI) និង AWSG ហើយមានបំណង ដើម្បីប្រមូលព័ត៌មានស្តីពីតំបន់សំខាន់ៗ សម្រាប់បង្កើតភាពជាដៃគូជាតិ និងអប់រំផ្សព្វផ្សាយជាមួយរដ្ឋាភិបាលមូលដ្ឋាន នៅក្នុងប្រទេសចិន និងកូរ៉េ ។

១០៦. កូរ៉េ (NIBR) និង WWF (ជប៉ុន) បានលើកឡើងថា អង្គការពួកគេ បានធ្វើការលើធនធានទីជម្រក និងការគ្រប់គ្រង និងកំណត់តំបន់សំខាន់ៗ នៅប្រទេសកូរ៉េ និងចិន ។

១០៧. អង្គការសត្វស្លាបកូរ៉េបានលើកឡើង អំពីគម្រោងអេកូឡូស៊ីសត្វសមុទ្រធំៗ នៅក្នុងសមុទ្រលឿង និងលើកទឹកចិត្តដៃគូរឱ្យផ្សារភ្ជាប់ការអភិរក្សសត្វស្លាបទឹកជាមួយនឹងគម្រោងនេះ និងគំនិតផ្តួចផ្តើមពាក់ព័ន្ធផ្សេងៗទៀត នៅតំបន់អេកូឡូស៊ី-សមុទ្រលឿង ។

## របៀបវារៈ ៣.៥. ២ ការអនុម័តនៃផែនការសកម្មភាព សម្រាប់សត្វស្លាបទឹកដែលរងការគម្រាមកម្ហែង : តួនាទី EAAFP

១០៨. ប្រធានប្រតិបត្តិបានបង្ហាញតម្រូវការដែលលើកឡើងថ្មីមួយ សំរាប់ EAAFP ដើម្បីកំណត់ថា តើវានឹងផ្តល់ការអនុម័តផ្លូវការដោយរបៀបណាចំពោះផែនការសកម្មភាពអន្តរជាតិ សំរាប់ប្រភេទសត្វស្លាបទឹក ដែលទទួលរងការគំរាមកំហែង ដែលបានរៀបចំក្រោមអាជ្ញាធរ CMS ។ ជាមួយនឹងសំណើពិសេស ដែលទទួលបាននាពេលថ្មីៗនេះ EAAFP ចាំបាច់ត្រូវយកចិត្តទុកដាក់ចំពោះទំនាក់ទំនងរបស់ខ្លួន ទៅនឹងក្រុមធ្វើផែនការដែលមានស្រាប់។ ការបង្កើតនៃក្រុមប្រតិបត្តិសម្រាប់ប្រធានបទនេះគឺត្រូវស្នើឡើង ។

១០៩. អង្គការ ICF បានរាយការណ៍អំពីកិច្ចពិភាក្សាទូទៅ លើប្រធានបទនេះ ដែលអនុវត្តនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងរបស់លេខាធិការដ្ឋាន នៅថ្ងៃមុនៗ ។ ការកត់សំគាល់មានបីកម្រិតដែលអាចសមរម្យនៅក្រោម EAAFP រួមមាន: ការអនុម័តយល់ព្រម ក្រុមប្រតិបត្តិ និងក្រុមការងារ ។ ផលប្រយោជន៍ទាំងសង្ខាង គឺត្រូវការ : ភាពជាដៃគូចាំបាច់ត្រូវជូនដំណឹងអំពីស្ថានភាព និងលទ្ធផល នៃសកម្មភាពដែលបានអនុម័តយល់ព្រម និងសកម្មភាពដែលបានរួមបញ្ចូលគ្នា ។

១១០. អង្គការជីវិតសត្វស្លាបអន្តរជាតិបានជំរុញឱ្យធ្វើការក្នុងរចនាសម្ព័ន្ធដែលមានស្រាប់ (ក្រុមការងារ) តាមតែអាចធ្វើទៅបាន និងប្រុងប្រយ័ត្នចំពោះការរីកលឿនពេក ហើយចរនាសម្ព័ន្ធ ដែលស្មុគស្មាញ ។

១១១. CMS បានផ្តល់អនុសាសន៍ថា ការអនុម័តយល់ព្រមនៃផែនការសកម្មភាព ការបន្ថែមលើការអនុម័តយល់ព្រមរបស់ CMS នឹងផ្តល់ផលប្រយោជន៍ចំពោះការអនុវត្ត។ វាគឺជាការសំខាន់ ដើម្បីស្វែងរកអង្គការមិនមែនរដ្ឋាភិបាល ឬ អ្នកជំនាញ ដើម្បីទទួលការអនុវត្ត (ឆ្ពោះទៅរកពានរង្វាន់) ផែនការសកម្មភាពដែលបានអនុម័ត ដោយ CMS ។

១១២ AEWA បានបន្ថែមថា EAAFP មិនអាចអនុម័តផ្លូវការនូវផែនការប្រភេទនីមួយៗបានទេ ពីព្រោះមិនដូច CMS ដែលវាមិនមានភាពជឿជាក់ពីរដ្ឋាភិបាល ដើម្បីធ្វើដូចនេះ។ EAAFP អាចអនុម័តលើការបង្កើតផែនការសកម្មភាព ពិភាក្សាអំពីសេចក្តីព្រាងផែនការ និងផ្តល់អនុសាសន៍ដល់រដ្ឋាភិបាល ដែលជាភាគីដៃគូ ដើម្បីទទួលយក (ឬ មិនទទួលយក) ។

១១៣. អង្គការ Wildfowl & Wetlands Trust បានលើកទឹកចិត្តលេខាធិការដ្ឋានឱ្យដកស្រង់ព័ត៌មាន ពី AEWA អំពីកម្រិតនៃការអនុម័តយល់ព្រមដែលបានប្រើប្រាស់ នៅតំបន់អាហ្វ្រិច–អាស៊ីអឺរ៉ុម ។ នេះ គឺត្រូវបានលើក

ទឹកចិត្ត ដោយ AEWA ។ ហើយ ជម្រុញឱ្យ EAAFP ធានានូវដំណើរការ ដែលបាននឹងកំពុងអនុវត្តផែនការសកម្មភាពមួយចំនួន ដែលបានអនុម័ត ។

១១៤. រុស្ស៊ីបានបន្ថែមទៀតថា ការព្រមព្រៀងផ្តល់ការគាំទ្រចាំបាច់ សំរាប់ការឆ្លើយតបនៅមូលដ្ឋាន ។ វាអាចជួយក្នុងការបកប្រែពាក្យបច្ចេកទេសអង់គ្លេសខ្លះ ដែលមានប្រើនៅក្នុងផែនការសកម្មភាព ។

១១៥. អង្គការ ICF បានរាយការណ៍ជូនអង្គប្រជុំស្តីពីការពិភាក្សារបស់ក្រុមប្រតិបត្តិ ដែលជាលទ្ធផលកិច្ចពិភាក្សាក្រុមតូច ។ ពាក្យថា "ក្រុមប្រតិបត្តិ" គឺ សមរម្យណាស់សម្រាប់ក្រុមដែលមានអាយុខ្លី ។ វាមាននៅក្នុងឯកសារភាពជាដៃគូ (អនុប្រយោគ ៩.៩ ) ។ អនុសាសន៍ចំនួន ៤ ត្រូវបានពង្រាងឡើង :

- ផែនការសកម្មភាព Scalysided Merganser អាចបង្កើតឡើងនៅក្រោមយន្តការនេះ និងស្លាកឃីហោ នៃអនុសញ្ញាស្តីពីប្រភេទដែលធ្វើទេសន្តរប្រវេសន៍ (CMS) និង ភាពជាដៃគូផ្លូវហោះហើរអូស្ត្រាលី–អាស៊ីខាងកើត (EAAFP) ដោយមានការពិគ្រោះយោបល់ និងគាំទ្រពីក្រុមការងារ Anatidae ព្រមទាំងអនុលោមតាមអនុសញ្ញាស្តីពីប្រភេទដែលធ្វើទេសន្តរប្រវេសន៍ ដើម្បីបង្កើតផែនការសកម្មភាព ។
- ដូចដែលផែនការសកម្មភាពនៃប្រភេទកុកចំពុះស្លាបព្រា ត្រូវបានបង្កើតឡើង ដោយអនុលោមតាមដំណើរការនៃអនុសញ្ញា CMS ដែលបានឯកភាព ក្រុមប្រតិបត្តិប្រភេទ នៃ EAAFP កុកចំពុះស្លាបព្រាគួរត្រូវបង្កើតឡើង ដោយមានការពិគ្រោះយោបល់ ក្រុមអនុសញ្ញាស្តីពីប្រភេទដែលធ្វើអន្តោប្រវេសន និងក្រុមការងារសត្វស្លាបតំបន់ឆ្នេរ។
- លេខាធិការដ្ឋានគួរត្រូវបង្កើតក្រុមការងារតូចមួយ ដើម្បីសង្ខេបឯកសារអំពីកិច្ចប្រជុំភាពជាដៃគូ លើកទី ៥ ដែលស្នើអោយមានដំណើររៀបចំផែនការសកម្មភាព សំរាប់ភាគីដៃគូផ្លូវហោះហើរអូស្ត្រាលី–អាស៊ីខាងកើត និង ដើម្បីបង្កើតគោលការណ៍ណែនាំសំរាប់រៀបចំល័ក្ខខ័ណ្ឌការងារ សំរាប់ក្រុមប្រតិបត្តិប្រភេទនីមួយៗ (ដោយយោងលើគំរូកិច្ចព្រមព្រៀង សត្វស្លាបទឹក African Eurasian (AEWA) ។
- ភាគីដៃគូ គួរប្រើប្រាស់ពាក្យសព្ទ នៅផ្នែកទី២ នៃឯកសារនេះ (ក្នុងកថាខណ្ឌ) ដែលពាក់ព័ន្ធនឹង ក្រុមការងារ និងក្រុមប្រតិបត្តិ អាណត្តិ និងការបន្ត នៃក្រុមប្រតិបត្តិ ត្រូវពិនិត្យឡើងវិញ រៀងរាល់ ៣ ឆ្នាំម្តង។

១១៦. ដៃគូបានយល់ព្រមចំពោះអនុសាសន៍ទាំងបួន ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមប្រតិបត្តិនឹងបញ្ចប់របាយការណ៍របស់ពួកគេ នៅក្រោយពេលប្រជុំនេះ ហើយគម្រោងស្នើសុំនឹងត្រូវលើកឡើង នៅក្នុងកិច្ចប្រជុំ លើកទី ៥ ។

**របៀបវារៈ ៣.៥.៣ ផែនការសកម្មភាពអន្តរជាតិ (អង្គការជីវិតសត្វស្លាបអន្តជាតិ–របាយការណ៍អាស៊ី)**

១១៧. អង្គការជីវិតសត្វស្លាបអន្តរជាតិបានធ្វើបទបង្ហាញអំពីផែនការសកម្មភាពអន្តរជាតិ សំរាប់សត្វស្លាបដែលទទួលរងការគំរាមកំហែង ៣ ប្រភេទ គឺ កុកជិពុះស្លាបព្រា (Black-faced Spoonbill) (ជិតផុតពូជ) ទីតលីតចំពុះស្លាបព្រា (Spoon-billed Sandpipers) (ជិតផុតពូជបំផុត) និងរំពេកំប៉ោយចិន (Chinese Crested Tern) (ជិតផុតពូជបំផុត) ។ ផែនការទាំងនេះបានអនុម័តយល់ព្រម ដោយ CMS ។ ផែនការទាំងនេះ គឺជាផលិតផលសំខាន់ ដែលបានមកពីការអញ្ជើញមួយ, ពី CMS ទៅអង្គការជីវិតសត្វស្លាបអន្តរជាតិ ដើម្បីដឹកនាំការងារស្តីពីសត្វស្លាបទឹកដែលរងការគំរាមកំហែងខ្ពស់ ៣ ប្រភេទ នៅក្នុងផ្លូវហោះហើរ ។ ចំពោះរំពេកំប៉ោយចិន សកម្មភាពនឹងត្រូវបានអនុវត្តរួមបញ្ចូលទាំងការបំពេញបន្ថែមនូវពត៌មានដែលខ្វះចន្លោះ ការការពារតំបនរីង និង ការអនុវត្តច្បាប់ ការអប់រំ និងបណ្តុះបណ្តាល។ ចំពោះ ប្រភេទកុកជិពុះស្លាបព្រា សិក្ខាសាលាអន្តរជាតិនឹងធ្វើឡើង នៅថ្ងៃទី ៤–៧ ខែមិនា ឆ្នាំ ២០១០ នៅ Fukuoka ។

១១៨. ក្រុមអនុសញ្ញាស្តីពីប្រភេទធ្វើទេសន្តរប្រវេសន៍បានធ្វើបទបង្ហាញ និងចែកចាយផែនការសកម្មភាពពាក់ព័ន្ធ (រំពេកំប៉ោយចិន (Chinese Crested Tern) ទីតលីតចំពុះស្លាបព្រា (Spoon-billed Sandpipers)) ជូនចំពោះប្រធានភាគីដៃគូ កូរ៉េ ឥណ្ឌូណេស៊ី ថៃ ភូមា និងបង់ក្លាដែស ។

១១៩. ប្រទេសថៃបានលើសំណើថា ផែនការសកម្មភាពប្រភេទអន្តរជាតិនឹងដាក់បញ្ចូលជាមួយនឹងផែនការសកម្មភាព និងយុទ្ធសាស្ត្រជីវៈចម្រុះថ្នាក់ជាតិរបស់ភាគីដៃគូ ក្រោមអនុសញ្ញាស្តីពីជីវៈចម្រុះ ។

**របៀបវារៈ ៣.៥.៤ ផែនការសកម្មភាពអន្តរជាតិ សំរាប់កុកចំពុះស្លាបព្រា *Spoon-billed Sandpipers***

១២០. ក្រុមដែលរកឃើញប្រភេទសត្វ *Spoon-billed Sandpipers* (Christoph Zockler) បានធ្វើបទបង្ហាញអំពីស្ថានភាពបច្ចុប្បន្ន ការថយចុះចំនួន ការគំរាមកំហែងលើទីតលីតចំពុះស្លាបព្រា Spoon-billed Sandpipers និងលើកឡើងអំពីសកម្មភាពផ្សេងៗទៀតរបស់ក្រុមនេះ។ ប្រភេទទាំងនេះនៅតែជាប្រភេទជិតផុតពូជបំផុត និងជួយសង្គ្រោះពីការបបាញ់នៅកន្លែងដែលសត្វរកចំណី ។ សកម្មភាពបន្ទាន់ដែលត្រូវការចាំបាច់ គឺ ការបង្កើនសមត្ថភាព ដើម្បីអប់រំជាសាធារណៈ ការអភិរក្ស និងការគ្រប់គ្រងទីជម្រក និងប្រភេទនៅតំបន់អាស៊ី

អាគ្នេយ៍ ជាពិសេស ប្រទេសភូមា ។ ក្រុមបានស្នើសុំឱ្យមានទម្រង់ នៃការរួមបញ្ចូលគ្នា នៃភាគីដៃគូផ្លូវហោះហើរ អាស៊ីខាងកើត និងអូស្ត្រាលី សមស្របមួយ។

១២១. ភាគីដៃគូបានយល់ព្រមលើសំណើរដែលបានលើកឡើងនេះ ហើយបានសួរទៅកាន់ក្រុមការងារ ដែលពាក់ព័ន្ធ ឱ្យដាក់បញ្ចូលវានៅការពិភាក្សារបស់ពួកគេ ក្នុងកំឡុងពេលនៃកិច្ចប្រជុំភាគីដៃគូលើកទីបួននេះ ។ វាត្រូវបានផ្តល់អនុសាសន៍ ដោយគណៈកម្មាធិការគ្រប់គ្រងនៃលេខាធិការដ្ឋាន កាលពីថ្ងៃមុនៗ ដែលការបង្កើតក្រុមការងារ ភាពជាដៃគូផ្លូវហោះហើរអូស្ត្រាលី–អាស៊ីខាងកើត ជាពិសេស សំរាប់ ប្រភេទនេះ គឺ មិនរឹងប៉ឹងដូច រចនាសម្ព័ន្ធភាពជាដៃគូផ្លូវហោះហើរអូស្ត្រាលី–អាស៊ីខាងកើត ។

**របៀបវារៈ ៣.៥.៥ ផែនការសកម្មភាពអន្តរជាតិ សំរាប់ Scaly-sided Merganser**

១២២. អង្គការស្មោះត្រង់តំបន់ដីសើម និងសត្វស្លាបទឹក (WWT) បានទាញការយកចិត្តទុកដាក់របស់ភាគីដៃគូ ចំពោះរបាយការណ៍ស្តីពីស្ថានភាពបច្ចុប្បន្ន ការធ្វើទេសន្តរប្រវេសន៍ ការថយចុះចំនួន និងការគំរាមកំហែងលើ Scaly-sided Merganser និងតម្រូវការវិធានការសំរាប់ការអភិរក្ស ។ ប្រភេទនេះមានការថយចុះ គឺដោយសារ មានការកាប់ឈើ ការបបាញ់ និងទឹកជំនន់ ។ អង្គការស្មោះត្រង់តំបន់ដីសើម និងសត្វស្លាបទឹក (WWT) បានស្នើសុំ ទៅភាគីដៃគូឱ្យផ្តល់ទម្រង់នៃការយល់ព្រមសមស្របមួយ ក្នុងពេលសិក្ខាសាលា នៅខែមេសា ឆ្នាំ២០១០ ដើម្បីរៀបចំផែនការសកម្មភាពអន្តរជាតិមួយ សម្រាប់ការស្តារឡើងវិញនៃប្រភេទនេះ ។

១២៣. អង្គការមូនិធិសត្វក្រៀលពិភពលោក បានផ្តល់អនុសាសន៍ ឱ្យរួមបញ្ចូលទាំង ការស្រាវជ្រាវ អំពីឥទ្ធិពល នៃ PCBs/ជាតិពុល ដែលមានលើប្រភេទនេះ។

១២៤. អង្គការជីវិតសត្វស្លាបអន្តរជាតិ និងក្រុមការងារសត្វអំបូរ Anatidae ដោយផ្អែកលើគំនិតផ្តួចផ្តើមដែលមានផែនការសកម្មភាព និងក្រុមប្រតិបត្តិប្រភេទនៃអំបូរ Anatidae ដែលជាប្រភេទទទួលរងការគំរាមកំហែង ដូចជា Swan Goose និង Baikal Teal ។ ក្រុមការងារ Anatidae បានបង្ហាញឆន្ទៈក្នុងការសហការធ្វើផែនការសកម្មភាពសំរាប់ប្រភេទសត្វ Scaly-sided Merganser និងធ្វើសំណើសុំខាន់សម្រាប់កំណត់ប្រភេទអាទិភាព ដែលតម្រូវឱ្យមានផែនការសកម្មភាព ។

១២៥. ភាគីដៃគូបានឯកភាពចំពោះសំណើរបស់អង្គការ WWT ដែលយល់ព្រមឱ្យមានសិក្ខាសាលា ហើយបានស្នើរសុំទៅក្រុមការងារ ដែលពាក់ព័ន្ធ ឱ្យដាក់បញ្ចូលទៅក្នុងការពិភាក្សា ក្នុងកិច្ចប្រជុំលើកទី ៤ ។

**ថ្ងៃទី ២ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១០**

**របៀបវារៈ ៣.៦ ដំណើរឆ្ពោះទៅសកម្មភាព ភាពជាភាគីដៃគូផ្លូវហោះហើរ   របាយការណ៍ពីការពិភាក្សាតាមក្រុម**

១២៦. ការពិភាក្សាតាមក្រុមត្រូវបានធ្វើឡើង ជាក្រុមតូចៗបួន ដោយផ្អែកលើក្រុមប្រតិបត្តិ ដែលបានកំណត់ ក្នុងកិច្ចពិភាក្សានៃកម្មវិធី សម្រាប់គោលបំណង ១-៥ និង/ឬ ពីកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងនៃលេខាធិការដ្ឋាន ដែលធ្វើឡើងថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១០ ។ គណៈនេះ ក្រុមបានធ្វើការរាយការណ៍ជូនកិច្ចប្រជុំពេញអង្គ ។ លទ្ធផលខាងលើ ត្រូវបានដាក់បញ្ចូល ទៅក្នុងកម្មវិធី ដែលទាក់ទង ។

- ក្រុមប្រតិបត្តិទី ១: ត្រួតពិនិត្យ និងតាមដានសត្វស្លាបទឹក និងឧបករណ៍សំរាប់គាំទ្រការសំរេចចិត្ត (៣.៣.៤) សម្របសម្រួលដោយ Doug Watkins ដែលមានអ្នកចូលរួមចំនួន ១៧នាក់
- ក្រុមប្រតិបត្តិទី ២: ការសម្របសម្រួល និងការពិនិត្យ មើលឡើងវិញនូវការដាក់ស្លាកពណ៌លើសត្វស្លាបទឹក (៣.៣.៦ ) សម្របសម្រួលដោយ Paul O'Neil ដែលមានអ្នកចូលរួមចំនួន ៨ នាក់។
- ក្រុមប្រតិបត្តិទី ៣: ទម្រង់នៃការយល់ព្រមរបស់ភាពជាភាគីដៃគូ សំរាប់ធ្វើផែនការសកម្មភាពប្រភេទ (៣.៥.២)សម្របសម្រួលដោយ Jim Harris &Christoph Zockler មានអ្នកចូលរួមចំនួន ១៤ នាក់។
- ក្រុមប្រតិបត្តិទី ៤: លក្ខខណ្ឌការងារ របស់គណៈកម្មាធិការគ្រប់គ្រងនៃលេខាធិការដ្ឋាន (៦.៣) សម្របសម្រួលដោយ Doug Alcorn មានអ្នកចូលរួមចំនួន ៥ នាក់។

**របៀបវារៈ ៤. ការបង្កើតភាពជាដៃគូ**

**របៀបវារៈ ៤.១ សំណើសុំជាដៃគូ ស្ថិតនៅក្រោមការពិចារណាសម្រាប់ដៃគូដែលមានសក្តានុពល**

១២៧. ប្រធានប្រតិបត្តិបានស្វាគមន៍ម្តងទៀត ចំពោះភាគីដៃគូថ្មី ដូចជា អង្គការ WWT ហើយបានពន្យល់ថា អង្គការនេះបានដំណើរការ និងមានសកម្មភាពជាច្រើន នៅក្នុងប្រទេសជាច្រើន ក្នុងផ្លូវហោះហើររបស់យើង ។ លោកកបានពន្យល់ផងដែរអំពីដំណើរការ ដាក់ពាក្យស្នើសុំ ដើម្បីក្លាយជាភាគីដៃគូថ្មី ដោយផ្អែកលើកថាខណ្ឌទី ៨ នៃឯកសារភាពជាភាគីដៃគូ និងបង្កើនការយកចិត្តទុកដាក់ ចំពោះការអនុវត្តរបស់ភាពជាភាគីដៃគូផ្លូវហោះហើរអូស្ត្រាលី-អាស៊ីខាងកើត ដែលបេក្ខភាពរបស់អង្គការមិនមែនរដ្ឋាភិបាលទាំងនោះ គួរមានសកម្មភាពដែលកំពុងបន្ត សម្រាប់សត្វស្លាបទឹកដែលធ្វើទេសន្តរប្រវេសន៍ យ៉ាងហោចណាស់ប្រទេសចំនួន ២ នៅក្នុងផ្លូវហោះហើរ ។

១២៨. អនុប្រធានអង្គប្រជុំបានបង្ហាញសៀវភៅហៅថា ការទំនាក់ទំនងដែលមិនអាចមើលឃើញ (Invisible Connection) ដល់ភាគីដៃគូដែលមានសក្តានុពលមានវត្តមាននៅក្នុងកិច្ចប្រជុំលើកទី ៤ នេះ ដែលមាន

ប្រទេសបង់ក្លាដែស ម៉ាឡេស៊ី និងមជ្ឈមណ្ឌលប្រចាំតំបន់រ៉ាមសារ អាស៊ីខាងកើត (សៀវនេះផលិតដោយអង្គការដីសើមអន្តរជាតិ ដោយមានការគាំទ្រ ពី Royal Dutch Shell និងបានចែកចាយនៅក្នុងកិច្ចប្រជុំរ៉ាមសារ CoP8 ហើមួយចំនួនទៀតត្រូវបានយកទៅចែកចាយ នៅកិច្ចប្រជុំលើកទី៤ ដោយអង្គការសត្វស្លាបកូរ៉េ) ។

១២៩. ប្រទេសថៃបានបង្ហាញឆន្ទៈរបស់ខ្លួន ដើម្បីក្លាយជាភាគីដៃគូមួយ ប្រសិនបើអាចអោយបានមុនកិច្ចប្រជុំលើកទី៥ ហើយបានពន្យល់អំពីដំណើរការផ្ទៃក្នុងរបស់រដ្ឋាភិបាលដែលត្រូវការចាំបាច់ ហើយ នេះរាប់បញ្ចូលទាំងការអនុម័តពីគណៈរដ្ឋមន្ត្រី ។ សិក្ខាសាលាថ្នាក់ជាតិ គឺមានប្រយោជន៍ណាស់សម្រាប់ថៃ ដើម្បីក្លាយជាសមាជិកដៃគូ ។

១៣០. អង្គការដីសើមអន្តរជាតិ បានសំណូមពរថា ព័ត៌មានស្តីពីដៃគូនីមួយៗ និងព័ត៌មានដែលពាក់ព័ន្ធរបស់ខ្លួនត្រូវដាក់លើគេហទំព័រ របស់ភាពជាភាគីដៃគូផ្លូវហោះហើរអាស៊ីខាងកើត និងអូស្ត្រាលី(EAAFP) ។

១៣១. លេខាធិការដ្ឋាននឹងតាមដានជាមួយភាគីដៃគូដែលមានសក្តានុពលទាំងអស់ រួមទាំងម៉ុងហ្គោលី និង វៀតណាម។

## របៀបវារៈ ៤.២ ឆ្លើយតបនឹងសំណើសម្រាប់កែលំអរស្ថានភាពនៃភាពជាភាគីដៃគូ

១៣២. ប្រធានប្រតិបត្តិបានពន្យល់ថា គាត់បានទទួលសំណួរដែលសួថា ហេតុអ្វីបានជាភាពជាដៃគូមិនមានស្ថានភាពដូច AEWA ឬ អង្គភាព UN ផ្សេងៗទៀត ។ គាត់បានរកឃើញយោបល់របស់ភាគីដៃគូ ថាតើគួរ ឬ មិនគួរដាក់សេចក្តីពន្យល់ ទៅលើគេហទំព័រ EAAFP ។

១៣៣. AEWA បានចង្អុលបង្ហាញថា EAAFP គឺ ផ្អែកលើអនុសារណយោគយល់គ្នា និងជាអង្គភាពមិនស្របច្បាប់ដែលអាស្រ័យលើសំណើនៃដៃគូដែលជាស្ថាបនិក ផ្ទុយទៅវិញ AEWA គឺជាកិច្ចព្រមព្រៀងគ្នាស្របច្បាប់ដែលភាគីតម្រូវឱ្យចូលរួមកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ។

១៣៤. អង្គការដីសើមអន្តរជាតិបានបញ្ជាក់ថា ការដាក់សេចក្តីពន្យល់នៅលើគេហទំព័រ នឹងផ្តល់ផលប្រយោជន៍ ដល់ដៃគូរដ្ឋាភិបាលដែលមានសក្តានុពល ដូចនេះគួរមានការចូលរួមចំណែកពីដៃគូរដ្ឋាភិបាលដែលមានស្រាប ។

១៣៥. ប្រធានប្រតិបត្តិបានប្រឹងប្រែងធ្វើការរៀបចំសេចក្តីព្រាង និងចែកជូនភាគីដៃគូ ដើម្បីពិនិត្យមើលជាមុនសិនមុនដាក់ផ្សាយ នៅលើគេហទំព័រ EAAFP ។

## របៀបវារៈ ៥ គម្រោងស្នើសុំដាក់លាក់ និងមូលនិធិដែលត្រូវការ

**របៀបវារៈ ៥.១ ដំណើការសម្រាប់ការស្នើសុំ និងការអនុម័តគម្រោង សំរាប់ផ្តល់មូលនិធិភាពជាភាគីដៃគូ**

១៣៦. ប្រធានប្រតិបត្តិបានផ្តល់យោបល់ដល់ភាគីដៃគូថា អរគុណចំពោះអនុស្សារណយោគយល់គ្នា (MOU) ជាមួយនឹងសាធារណៈរដ្ឋកូរ៉េ ដែល EAAFP អាចទទួលបានមូលនិធិចំនួន ១០០ លាន KRW សំរាប់សកម្មភាពភាពជាភាគីដៃគូនៅឆ្នាំ ២០១០។ ប្រហែលពាក់កណ្តាល នៃថវិកា សំរាប់បម្រុងទុកការចំណាយលើកិច្ចប្រជុំ ប៉ុន្តែ ផ្នែកដែលនៅសល់ បានយកទៅប្រើប្រាស់ដោយផ្ទាល់ សំរាប់សកម្មភាពផ្សេងៗ ដោយភាគីដៃគូក្នុងពេលប្រជុំលើកទី ៤ ។ លើសពីនេះទៀត លេខាធិការដ្ឋានមិនមានបំណងធ្វើជាអង្គភាពផ្តល់មូលនិធិទេ និងបានចាប់ផ្តើមទទួលមូលនិធិបន្ថែម ហើយគួរតែមានទម្រង់ការមួយសម្រាប់អនុម័តគម្រោង សំរាប់ការផ្តល់មូលនិធិភាពជាដៃគូ ។ គម្រោងស្នើសុំត្រូវបានបង្ហាញ នៅក្នុងកិច្ចប្រជុំលើកទី ៣ ប៉ុន្តែគ្មានគម្រោងណាមួយ ត្រូវបានដាក់ស្នើសម្រាប់ការធ្វើការពិចារណា នៅកិច្ចប្រជុំលើកទី ៤ ទេ ។

១៣៧. AEWA បានស្នើឡើងថា សំណើសុំគួរយកទៅពិចារណានៅក្នុងកិច្ចប្រជុំភាគីដៃគូនីមួយៗ ហើយគម្រោងដែលបានអនុម័តយល់ព្រម ត្រូវផ្តល់មូលនិធិតាមការសម្រេចរបស់ប្រធានប្រតិបត្តិ នៅពេលដែលប្រាក់អាចរកបាន។

១៣៨. តាមរយៈការអញ្ជើញរបស់អង្គការដីសើមអន្តរជាតិ WWF (ហុងកុង) បានពន្យល់អំពីការផ្តល់មូលនិធិខ្នាតតូចរបស់ខ្លួន ដែលបង្កើតមូលនិធិបានពីអង្គការ Cathay Pacific ដើម្បីទ្រទ្រង់សកម្មភាពភាគីដៃគូផ្លូវហោះហើរ។ គម្រោង ២ ឬ ៣ (ប្រហែល ៤០០០ ដុល្លា) ត្រូវបានផ្តល់មូលនិធិក្នុងរយៈពេលមួយឆ្នាំ ។

១៣៩. លេខាធិការដ្ឋានរ៉ាមសារ បានរំលឹកថា EAAFP មិនមានបំណងផ្តល់ជំនួយខ្នាតតូច និងទាញការយកចិត្តទុកដាក់ លើមូលនិធិពិភពលោកជំនួយខ្នាតតូចរ៉ាមសារ ។

១៤០. មជ្ឍមណ្ឌលរ៉ាមសារប្រចាំតំបន់អាស៊ីខាងកើត បានពន្យល់ថា គេបានគាំទ្រគម្រោង នៅប្រទេសម៉ុងហ្គោលី និងកូរ៉េខាងជើង នៅឆ្នាំ ២០០៩ ហើយនឹងគាំទ្រគម្រោងយ៉ាងហោចណាស់ចំនួន ៣ (មានទឹកប្រាក់ ១០០០០ ដុល្លា ក្នុងគម្រោងនីមួយៗ) នៅឆ្នាំ ២០១០ ។ គេអាចបន្ថែមគម្រោង សំរាប់ក្រុមប្រតិបត្តិតាមប្រភេទនីមួយៗ ទៀត ។

១៤១. ក្រុម Spoonbilled Sandpiper Recovery បានជំរុញឱ្យ EAAFP ស្វែងរកមូលនិធិពីអ្នកផ្តល់ជំនួយរួមគ្នា និងផ្តល់ប្រឹក្សាថា មូលនិធិធំៗ គឺត្រូវការចាំបាច់សម្រាប់អនុវត្ត ផែនការសកម្មភាពប្រភេទ ។

១៤២. បង់ក្លាដែស បានបញ្ជាក់ថា ការគាំទ្រមូលនិធិពីអង្គការខាងក្រៅ អានាំឱ្យមានការសន្យាផ្តល់ថវិកា របស់រដ្ឋាភិបាល ដើម្បីអនុវត្តផែនការសកម្មភាព ឬ កសាងសមត្ថភាព ។

១៤៣. ជប៉ុនបានផ្តល់អនុសាសន៍លើមូលនិធិដែលបានបង្កើតឡើងល្អពីរ គឺ : មូលនិធិជប៉ុនសំរាប់បរិស្ថានពិភពលោក និងមូលនិធិអភិរក្សធម្មជាតិ Keidanren ។

១៤៤. តាមរយៈសំណើរបស់រ៉ាមសារ លេខាធិកាដ្ឋាននឹងបង្កើតទំនាក់ទំនង គេហទំព័ររបស់ EAAFP ជាមួយនឹងមូលនិធិខ្នាតតូច ។

## របៀបវារៈទី ៥.២ គម្រោងស្នើសុំការគាំទ្រមូលនិធិភាពជាដៃគូដែលអាចទទួលបាន

១៤៥. សហរដ្ឋអាមេរិចបានស្នើឡើងថា ផ្អែកលើលក្ខណៈវិនិច្ឆ័យ ប្រធានប្រតិបត្តិ គួរតែមានសិទ្ធិអំណាចក្នុងការសម្រេច លើការចាត់ចែងមូលនិធិមួយចំនួនតូច ទៅឱ្យគម្រោងផ្លូវហោះហើរ ដែលស៊ីគ្នានឹងផែនការរបស់លេខាធិការដ្ឋាន ។ គណៈកម្មាធិការគ្រប់គ្រងនៃលេខាធិការដ្ឋានអាចធ្វើការគាំទ្រ ដល់ការសម្រេចចិត្តនៅក្រៅអង្គប្រជុំ ប្រសិនបើជាការចាំបាច់ ។

## របៀបវារៈទី៦: រដ្ឋបាលភាពជាដៃគូផ្លូវហោះហើរ

## របៀបវារៈទី៦.១ ការត្រួតពិនិត្យ មើលឡើងវិញនៃការប្រតិបត្តិរបស់លេខាធិការដ្ឋាន

១៤៦. ប្រធានប្រតិបត្តិ បានរាយការណ៍សង្ខេបស្តីពីប្រព័ន្ធប្រតិបត្តិការនៃលេខាធិការដ្ឋានដ្ឋាន ដោយបានបញ្ជាក់អំពីប្រព័ន្ធរដ្ឋបាល និងហិរញ្ញវត្ថុ។ ប្រព័ន្ធជាច្រើន យកគំរូតាមប្រព័ន្ធរបស់រដ្ឋាភិបាលកូរ៉េ នៅពេលបច្ចុប្បន្ន ។ បញ្ហាប្រឈមប្រតិបត្តិការដែលនៅសល់មួយចំនួន នឹងត្រូវបានដោះស្រាយជាបណ្តើរៗ ដូច្នេះ លេខាធិការដ្ឋានត្រូវធ្វើឱ្យមានលក្ខណៈស្របគ្នាទៅនឹងអង្គការអន្តរជាតិមួយ។ ជាឧទាហរណ៍ ផ្ទេរទៅជាប្រព័ន្ធគណនេយ្យត្រឹមត្រូវមួយ ត្រូវបានស្នើឡើង ។

## របៀបវារៈទី៦.២ ការផ្តល់អំណាចរវាងប្រធាន និងប្រធានប្រតិបត្តិ

១៤៧. ប្រធានប្រតិបត្តិបានស្នើសុំឱ្យដៃគូនានា ពិចារណាថា តើអ្វីដែលត្រូវចុះហត្ថលេខា ដោយប្រធានប្រតិបត្តិ និងអ្វីដែលត្រូវចុះហត្ថលេខា ដោយប្រធាននៃភាពជាដៃគូ ។

១៤៨. សហរដ្ឋអាមេរិចរាយការណ៍ថា លទ្ធផលនៃការពិភាក្សាបញ្ហានេះ ក្នុងអំឡុងពេលកិច្ចប្រជុំនៃគណៈកម្មធិការគ្រប់គ្រង កាលពីថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១០ បានកត់សម្គាល់ឃើញថា បញ្ហានានាក្នុងកម្រិតភាពជាដៃគូ ជាទូទៅ ប្រធាន គឺជាអ្នកចុះហត្ថលេខា ចំណែកឯបញ្ហាភាគច្រើននៃលេខាធិការដ្ឋាន

អាចចុះហត្ថលេខា ដោយប្រធានប្រតិបត្តិ ។ ប្រធាននឹងអនុម័តលើការសម្រេចចិត្តជ្រើសរើសទីតាំងបណ្តាញថ្មី និងដៃគូថ្មីនានា និងចុះហត្ថលេខាលើឯកសារផ្លូវការនានាដែលទាក់ទងបញ្ហានេះ។ ប្រធានប្រតិបត្តិនឹងតែងតាំងបុគ្គលិក បើកគណនេយ្យធនាគារ ចុះហត្ថលេខាលើកិច្ចសន្យានៃការផ្តល់មូលនិធិ និងគម្រោងនានា និងសន្យាចំពោះការចំណាយ លើកលែងតែការអនុម័តរបស់គណៈកម្មាធិការគ្រប់គ្រងដែលត្រឹមត្រូវ ។ ការចេញផ្សាយសារព័ត៌មាន ដោយប្រធានប្រតិបត្តិ គួរត្រូវចម្លងជូនដៃគូដែលពាក់ព័ន្ធ ។ ភាពជាដៃគូពេញលេញ គួត្រូវធ្វើការពិគ្រោះយោបល់ នៅពេលដែលមានភាពមិនប្រាកដប្រជា ជាដុំកំភួននោះ។

១៤៩. ដៃគូបានយល់ព្រមថា ប្រធានប្រតិបត្តិគួរធ្វើការជាមួយគណៈកម្មាធិការគ្រប់គ្រង ដើម្បីបំពេញបញ្ជី នៃស៊ុណារីយ៉ូ និងការផ្តល់សិទ្ធិអំណាច។

## របៀបវារៈទី៦.៣ លក្ខខ័ណ្ឌការងារ និងការតែងតាំងគណៈកម្មាធិការគ្រប់គ្រង

១៥០. ប្រធានប្រតិបត្តិបានរាយការណ៍ថា គណៈកម្មាធិការគ្រប់គ្រង ដើរតួនាទីគាំទ្រ និងផ្តល់ដំបូន្មានដ៏មានតម្លៃដល់ប្រធានប្រតិបត្តិ និងលេខាធិការដ្ឋានដ្ឋាន ។ លក្ខខ័ណ្ឌការងារសម្រាប់គណៈកម្មាធិការ ត្រូវបានរៀបចំឡើងដែលជាលទ្ធផលនៃកិច្ចប្រជុំភាគីដៃគូលើកទី ៣ (MoP3) ជាពិសេស ទាក់ទងទៅនឹងការដោះស្រាយបុគ្គលិករបស់លេខាធិការដ្ឋាន ។ សមាជិកគណៈកម្មាធិការមួយចំនួន បានស្នើសុំថា ដើម្បីដោះស្រាយតួនាទីជាបន្តដែលមានការផ្លាស់ប្តូរ នៃគណៈកម្មាធិការ លក្ខខ័ណ្ឌនានាដូច ជាដំណើរការសម្រាប់ការតែងតាំងគណៈកម្មាធិការ គួរតែធ្វើការត្រួតពិនិត្យឡើងវិញ។

១៥១. ក្រុមការងារ ដែលដឹកនាំដោយសហរដ្ឋអាមេរិក បានផ្តួចផ្តើមគំនិតនៃដំណើរការនៃការត្រួតពិនិត្យមើលឡើងវិញ នូវលក្ខខ័ណ្ឌការងារ នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រង នៅថ្ងៃទី ២២ កុម្ភៈ ដែលទាក់ទងទៅនឹងការផ្តល់សេចក្តីព្រាងចុងក្រោយសម្រាប់ការអនុម័ត នៅក្នុងកិច្ចប្រជុំ MoP5 ។ ខ្លឹមសារសំខាន់ៗ ដែលបានពិភាក្សាដោយក្រុមប្រតិបត្តិ ក្នុងកិច្ចប្រជុំលើកទី ៤ នៅពេលបែងចែកក្រុមពិភាក្សា រួមមាន : សេចក្តីថ្លែង – ការណ៍នៃគោលបំណង ការរៀបចំប្រធានអង្គប្រជុំ ការជ្រើសរើសសមាសភាព ការធ្វើការសំរេចចិត្ត ការតែងតាំងសមាជិក និងការប្តូរវិលជុំ គូរ៉ុមសំរាប់ឆ្លើយតបអ៊ីម៉ែលដែលផ្ញើដោយប្រធានប្រតិបត្តិ រយៈពេលនៃការឆ្លើយតប និងការត្រួតពិនិត្យហិរញ្ញវត្ថុ ។ សេចក្តីព្រាងថ្មីដែលមិនទាន់ពេញលក្ខណៈត្រូវបានពិភាក្សាក្នុងកិច្ចប្រជុំពេញអង្គលើកទី ៤ (របៀបវារៈ ៣.៦)។

១៥២. ភាគីដៃគូបានយល់ថា វត្តមាននៃសមាជិកទាំង ៨ នាក់នៃគណៈកម្មាការ នឹងបន្តរក្សារហូតដល់មានល័ក្ខខ័ណ្ឌការងារថ្មី ត្រូវបានអនុម័ត នៅក្នុងដំណើរការនៃការពិនិត្យ ឡើងវិញ។

**ប្រៀបវារៈ ៦.៤ លក្ខណៈវិនិច្ឆ័យសំរាប់ផ្តល់មូលនិធិគាំទ្រសម្រាប់ការចូលរួមប្រជុំរបស់ភាគីដៃគូ**

១៥៣. ប្រធានប្រតិបត្តិបានបង្កើតសនិទានសង្ខេប បែងចែកមូលនិធិគាំទ្រដៃគូ ដើម្បីចូលរួមកិច្ចប្រជុំលើកទី ៤ ។ គណៈកម្មការគ្រប់គ្រងបានធ្វើការត្រួតពិនិត្យ ឡើងវិញអំពីផែនការទាំងនេះនៅថ្ងៃទី ២២ ខែកុម្ភៈ។

១៥៤. អង្គការដីសើមអន្តរជាតិបានផ្តល់អនុសាសន៍ដល់គណៈកម្មការ ដើម្បីស្នើឱ្យប្រធានប្រតិបត្តិ បញ្ចូល នូវការពិនិត្យ ឡើងវិញ នៃការពិចារណាដែលជាយុទ្ធសាស្រ្តរយៈពេលវែង ក្នុងការផ្តល់មូលនិធិ ជាពិសេសផ្តោតលើភាគីដៃគូ ដែលមានសក្តានុពល ។

១៥៥. BANCA (អង្គការមិនមែនរដ្ឋាភិបាល នៅភូមា) បានថ្លែងអំណរគុណចំពោះភាគីដៃគូការងារទាំងអស់ ដែលបានផ្តល់ការគាំទ្រនៅក្នុងការចូលរួមកិច្ចប្រជុំលើកទី៤ និងគណៈកម្មការដែលបានធ្វើរបាយការណ៍ ទៅកាន់រដ្ឋាភិបាល ភូមា។

**របៀបវារៈ ៦.៥ ផែនការរបស់លេខាធិការដ្ឋាន សំរាប់ឆ្នាំ ២០១០ ត្រូវកែសម្រួល ដោយផ្អែកលើលទ្ធផលប្រជុំ**

១៥៦. ប្រធានប្រតិបត្តិបានចែកសេចក្តីព្រាងផែនការរបស់លេខាធិការដ្ឋានសំរាប់ឆ្នាំ ២០១០ ជូនភាគីដៃគូ ។ សេចក្តីព្រាងនេះ គឺ ផ្អែកលើតួនាទីរដ្ឋបាល និងគោលបំណងទាំង ៥ នៃភាពជាដៃគូ ។ សេចក្តីព្រាងនេះត្រូវបានពិនិត្យ ឡើងវិញ និងផ្តល់ការអនុម័តយល់ព្រមជាទូទៅ នៅពេលថ្មីៗ ដោយគណៈកម្មការគ្រប់គ្រង ។ ការកែប្រែគួរត្រូវធ្វើ ដោយប្រធានប្រតិបត្តិ ដោយអនុលោមតាមវិធានការដែលបានលើកឡើងក្នុងកិច្ចប្រជុំលើកទី ៤ ។

១៥៧. AEWA ជួយគាំទ្រ លេខាធិការដ្ឋានតាមដានបញ្ហា និងការអភិវឌ្ឍ នៅទូទាំងតំបន់ផ្លូវហោះហើរ និងគួរដឹងអំពីប្រតិទិន នៃអង្គការតំបន់ និងអង្គការអន្តរជាតិ ដែលទាក់ទង ។

១៥៨. លេខាធិការដ្ឋានរ៉ាមសារ ដែលគាំទ្រដោយអង្គការដីសើមអន្តរជាតិ បានផ្តល់អនុសាសន៍ ធានាការផ្លាស់ប្តូរ និងការទំនាក់ទំនងជាមួយដៃគូអាស៊ាន ដែលពាក់ព័ន្ធ និងយន្តការពិភពលោក ។ (ក្រុមការងារអាស៊ានស្តីពីជីវៈចម្រុះ, បណ្តាញមណ្ឌលបំរុងសត្វស្លាបតំបន់ឆ្នេរអឌ្ឍគោលខាងលិច និងផលិតព្រឹត្តិបត្រព័ត៌មាន ។

១៥៩. AWSG បានផ្តល់យោបល់ថា ព្រឹត្តិបត្រព័ត៌មាន គួរត្រូវដាក់បង្ហាញនៅលើគេហទំព័រ ឬ ផ្ញើតាមរយៈ អ៊ីម៉ែល។

១៦០. ភាគីដៃគូបានស្នើឱ្យមានការកែតម្រូវផែនការ ដើម្បីផ្តល់កាតព្វកិច្ចរដ្ឋបាលរបស់លេខាធិការដ្ឋានឱ្យបានប្រសើរឡើង និងធានាថា ផែនការនេះ ជៀសវាងបាននូវវិធានការដែលជាការទទួលខុសត្រូវរបស់ភាគីដៃគូ ។

១៦១. ប្រទេសបង់ក្លាដែស បានផ្តល់យោបល់ថា លេខាធិការដ្ឋានគួរផ្តល់ព័ត៌មានថ្មីៗ និងការទំនាក់ទំនងជាប់ជានិច្ចជាមួយនឹងមន្ត្រីបង្គោលEAAFP នីមួយៗ ។

១៦២. អង្គការតំបន់ដីសើមអន្តរជាតិបានកត់សំគាល់ឃើញថា ភាគីដៃគូអាចជួយលេខាធិការដ្ឋាន ក្នុងការទំនាក់ទំនង ហើយរ៉ាមសារ (លោក Lew Young ) ចង់បង្កើតព្រឹត្តិបត្រព័ត៌មានស្តីអំពីរ៉ាមសារ ។

១៦៣. AWSG បានស្នើឱ្យថែរក្សាអន្តរសកម្មភាពរបស់លេខាធិការដ្ឋាន ឱ្យស្របនឹងគោលដៅ នៃភាពជាភាគីដៃគូ។

១៦៤. អង្គការដីសើមអន្តរជាតិបានស្នើឡើងថា ដោយសារតែ EAAFP កំពុងធ្វើការដែលសំដៅឱ្យដៃគូធ្វើការសហប្រតិបត្តិការបន្ថែមទៀត ផែនការនឹងត្រូវបង្កើតឡើង ក្នុងទម្រង់ផ្សេងៗគ្នា នៅអនាគត ដ៏ខ្លីខាងមុខនេះ។

១៦៥. លេខាធិការដ្ឋានរ៉ាមសារបានផ្តល់យោបល់ថា ការងាររបស់អង្គការអន្តរជាតិដែលផ្សារភ្ជាប់នឹងដីសើម គឺទំនាក់ទំនងនឹង EAAFP ហើយ WLI កំពុងមានសកម្មភាពនៅអាស៊ី និងប្រហែលជា ពេលក្រោយ គេមានកិច្ចប្រជុំ នៅប្រទេសម៉ាឡេស៊ី នៅក្នុងឆ្នាំ ២០១០។

## **របៀបវារៈ ៦.៦: ថវិការបស់លេខាធិការដ្ឋានសំរាប់ឆ្នាំ ២០១០: ត្រូវកែប្រែ អនុលោមតាមផែនការ និងលទ្ធផលនៃកិច្ចប្រជុំ**

១៦៦. ប្រធានប្រតិបត្តិបានចែកចាយសេចក្តីព្រាងផែនការថវិការបស់លេខាធិការដ្ឋាន សំរាប់ឆ្នាំ២០១០ ជូនភាគីដៃគូ ហើយ សេចក្តីព្រាងនេះ គឺផ្អែកលើអនុស្សារណៈយោគយល់គ្នា (MoU) (មូលនិធិស្នូលរបស់កូរ៉េ) និងត្រូវបានពិនិត្យឡើងវិញ និងអនុម័តយល់ព្រមជាទូទៅ ដោយគណៈកម្មការគ្រប់គ្រង នៅពេលថ្មីៗនេះ។ លោកបានពន្យល់អំពីតម្រូវការកែសម្រួលចំនួនទឹកប្រាក់ នៅក្នុងចំនួនសរុប ដូចគ្នា (៥០៩ លាន KRW) និងមិនកែប្រែចំនួនទឹកប្រាក់សំរាប់បុគ្គលិក ឬ សកម្មភាពរបស់ភាពជាដៃគូសំខាន់ គឺ ដោយសារ ថ្លៃឈ្នួលការិយាល័យខ្ពស់ពេក ចាប់តាំងពីការផ្តើមអនុវត្ត នៅខែកក្កដា ឆ្នាំ២០០៩មកម្លេះ ។

១៦៧. AEWA បានផ្តល់អនុសាសន៍ឱ្យបន្ថែមកូឡោន ដើម្បីបញ្ជាក់ចំនួនទឹកប្រាក់ ជាដុល្លា ។

១៦៨. អូស្ត្រាលីបានគាំទ្រថា ប្រធានប្រតិបត្តិអាចកំណត់ការកែសម្រួលថវិកា នៅក្នុងប្រាក់សរុបទាំងអស់ ។

១៦៩. ភាគីដៃគូបានព្រមព្រៀងលើការកែតម្រូវថវិកា (នៅក្នុងសរុបដែលមាន) ដែលបានបង្ហាញ ដោយប្រធាន ។

**របៀបវារៈ៧ : កិច្ចការផ្សេងៗទៀត**

១៧០. ដោយមានការយល់ព្រមពីតំណាងរដ្ឋាភិបាលកូរ៉េ បណ្តាញអង្គការមិនមែនរដ្ឋាភិបាលដីសើមកូរ៉េ បានធ្វើបទបង្ហាញវីដីអូខ្លី និងរបាយការណ៍ (អានដោយបណ្ឌិត Han DongUk នៃ PGAI ប្រទេសកូរ៉េ) ស្តីពីការគម្រាមកំហែងលើសត្វក្រៀល នៅទន្លេណាក់ដុង (Nakdong River) (ទីតាំងបណ្តាញ) ដោយសារគម្រោងទន្លេ ៤ ។ KWNN បានស្នើឱ្យភាគីដៃគូសរសេរលិខិត ទៅរដ្ឋាភិបាលកូរ៉េ ដើម្បីទាមទារឱ្យមានការការពារនៃ តំបន់នេះ។

១៧១. អង្គការដីសើមអន្តរជាតិ បានរាយការណ៍អំពីការពិភាក្សានាពេលថ្មីៗនេះ ជាមួយនឹងអង្គការជីវិតសត្វស្លាបអន្តរជាតិ និងកិច្ចព្រមព្រាងរបស់ពួកគេ ដើម្បីរៀបចំកិច្ចប្រជុំបច្ចេកទេសមួយ ក្នុងគោលបំណងបង្រួបបង្រួមរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីលើកស្ទួយ រឺ ពង្រឹងតំបន់បណ្តាញផ្លូវហោះហើរ និងដើម្បីពង្រឹងការតាមដាន និង បង្កើតគម្រោងថ្នាក់តំបន់ ។ គំនិតគម្រោងស្នើសុំ (Concept proposal) គួរត្រូវរៀបចំឡើង ឥឡូវនេះ ដើម្បីស្វែងរកការចាប់អារម្មណ៍របស់ក្រុមប្រឹក្សា GEF និងអ្នកផ្តល់មូលនិធិរួមគ្នា ដែលមានសក្តានុពលភាព ។ លេខាធិការដ្ឋានរ៉ាមសារ និង CMS/AEWA បានសម្តែងនូវការចាប់អារម្មណ៍របស់ពួកគេ ក្នុងការគាំទ្រការដឹកនាំរបស់អង្គការដីសើមអន្តរជាតិ នៅផ្នែកនេះ ។ រុស្ស៊ីបានទទួលការបកស្រាយបំភ្លឺ ដែលទាក់ទងនឹង GEF រួមមាន ការប្រែប្រួលអាកាសធាតុ និងប្រព័ន្ធអេកូឡូស៊ីសមុទ្រ ។

១៧២ AEWA បានអញ្ជើញប្រធានប្រតិបត្តិឱ្យធ្វើបទបង្ហាញអំពីភាពជាដៃគូផ្លូវហោះហើរអូស្ត្រាលី–អាស៊ីខាងកើត នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ លើកទី ១៥ នៃ AEWA ថ្ងៃទី ១៤–១៥ មិថុនា ២០១០ នៅក្រុង Hague ប្រទេស Netherlands ។ AEWA បានផ្តល់ព័ត៌មានដល់ភាគីដៃគូផងដែរ អំពីសកម្មផ្សេងទៀត រួមមាន ការបង្កើតផ្លូវហោះហើរអាស៊ីកណ្តាល និងការបង្កើតគោលការណ៍ណែនាំ ដើម្បីរៀបចំប្រព័ន្ធខ្សែភ្លើងដែលនៅជិត ទីជម្រកសត្វស្លាបទឹក ។ បានផ្តល់អនុសាសន៍ឱ្យចូលរួម ទិវាសត្វស្លាបទឹកទេសន្តរប្រវេសន៍ពិភពលោក (ថ្ងៃទី៨–៩ ខែឧសភា ឆ្នាំ ២០១០)។

១៧៣. ប្រធានប្រតិបត្តិបានសុំការយល់ព្រមរបស់អ្នកធ្វើបទបង្ហាញ ដែលបទបង្ហាញរបស់ពួកគេអាចត្រូវបានចែកជូនអ្នកចូលរួម ដែលបានចុះឈ្មោះក្នុងកិច្ចប្រជុំលើកទី ៤ ប្រសិនបើ ត្រូវបានស្នើសុំ ។ អង្គការជីវិតសត្វស្លាប

អន្តរជាតិបានយល់ស្របថា ឯកសារទាំងនោះ គឺ សំរាប់ប្រើប្រាស់ជាលក្ខណៈបុគ្គលតែប៉ុណ្ណោះ ហើយប្រហែលជា ត្រូវមានកម្មសិទ្ធិបញ្ញា សម្រាប់រូបថតមួយចំនួន។

១៧៤. ប្រទេសបង់ក្លាដែស បានស្នើឱ្យធ្វើសេចក្តីប្រកាស ពីកិច្ចប្រជុំលើកទី ៤ ។ AEWA បានតបវិញថា ការផ្សាយសារព័ត៌មាន គឺសមស្របជាង ហើយប្រធានប្រតិបត្តិបានផ្តល់យោបល់ថា ក្រសួងបរិស្ថាន កូរ៉េ បានបញ្ជាក់ថា វាគួរតែធ្វើការផ្សាយព័ត៌មាន នៅពេលខ្លីខាងមុខនេះ ។

១៧៥. AWSG បានសង្ខេបជូនដៃគូដែលមានចំណាប់អារម្មណ៍អំពីការទទួលបានទិន្នន័យ និងការធ្វើទេសន្តរប្រវេសន៍ បន្ទាប់ពីបិទកិច្ចប្រជុំ ។

## របៀបវារៈ ៨ កិច្ចប្រជុំនាពេលបន្ទាប់

១៧៦. អនុប្រធានបានផ្តល់យោបល់ថា គ្មានការផ្តល់ឱ្យធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំភាគីដៃគូ នៅពេលបន្ទាប់ បាននឹងកំពុងទទួលឡើយ ។ ប្រធានប្រតិបត្តិបានពន្យល់ថា ភាគីដៃគូ រាប់បញ្ចូលទាំង អង្គការមិនមែនរដ្ឋាភិបាល នឹងអាចត្រូវបានផ្តល់ឱ្យធ្វើជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំភាគីដៃគូនេះ។

១៧៧. កម្ពុជាត្រូវបានផ្តល់ឱ្យធ្វើជាម្ចាស់ផ្ទះសំរាប់កិច្ចប្រជុំភាគីដៃគូលើកទី ៥ ដែលត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីជាមុនសិន នៅក្រោយពីការត្រឡប់ពីកិច្ចប្រជុំលើកទី ៤ នៃគណៈប្រតិភូ ។ កាលបរិច្ឆេទនៃកិច្ចប្រជុំនៅក្នុងវិច្ឆិកា ឬ ខែធ្នូ គឺ ជាពេលដ៏សមស្របបំផុត ។ ភាគីដៃគូបានសម្តែងនូវការអបអរសាទរ ចំពោះការផ្តល់ឱ្យនេះ ហើយប្រធានប្រតិបត្តិបានកត់សម្គាល់ថា វាជាយុទ្ធសាស្ត្រសំខាន់មួយ ដែលមានកិច្ចប្រជុំនៅតំបន់អាស៊ីអាគ្នេយ៍ ដើម្បីលើកស្ទួយភាគីដៃគូ នៅទីនោះ។

១៧៨. សហរដ្ឋអាមេរិចបានសម្តែងនូវក្តីសង្ឃឹមថា ធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំភាគីដៃគូ នៅអនាគត នៅ អាឡាស្កា ប៉ុន្តែបានផ្តល់យោបល់ថា ធ្វើនៅរដូវក្តៅ គឺជាពេលមួយដ៏ប្រសើរ។ ប្រសិនបើ ធ្វើនៅខែមិថុនា ឬ ខែកក្កដា គឺប្រសើរណាស់ ដែលសហរដ្ឋអាមេរិចចង់ធ្វើជាម្ចាស់ផ្ទះ សំរាប់កិច្ចប្រជុំលើកទី ៦ ។

១៧៩. ប្រធានប្រតិបត្តិបានផ្តល់អនុសាសន៍ថា គណៈកម្មការគ្រប់គ្រង បានបញ្ជាក់សារជាថ្មីថា (ដូចឯកសាររបស់ភាពជាដៃគូ) មិនទាន់មានកំណត់កាលបរិច្ឆេទ (ខែ) សំរាប់កិច្ចប្រជុំភាគីដៃគូ និងសំខាន់គួរត្រូវមានថវិកាលេខាធិការដ្ឋានគ្រប់គ្រាន់ ដើម្បីរៀបចំកិច្ចប្រជុំលើកទី ៥ ក្នុងឆ្នាំ ២០១០ ។ គាត់នឹងទាក់ទងប្រទេសកម្ពុជា ដើម្បីបញ្ជាក់អំពីការផ្តល់ឱ្យធ្វើជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំលើកទី ៥ នេះ ប្រសិនបើអាចធ្វើទៅបាន នៅខែវិច្ឆិកា ឬ ខែធ្នូ ឆ្នាំ ២០១០ ។

១៨០. អង្គការដីសើមអន្តរជាតិបានស្នើឡើងថា កិច្ចប្រជុំក្រុមការងារ EAAFP ផ្សេងៗ គួរត្រូវធ្វើឡើងមួយថ្ងៃ ឬច្រើនថ្ងៃ នៅមុនពេលចាប់ផ្តើមនៃកិច្ចប្រជុំលើកទី ៥ ។

**របៀបវារៈ ៩. បិទអង្គប្រជុំ**

១៨១. អនុប្រធាន និងប្រធានប្រតិបត្តិបានថ្លែងអំណរគុណដល់ដៃគូទាំងអស់ ចំពោះការចូលរួមរបស់ពួកគេ និងធ្វើការងារយ៉ាងលំបាក នៅក្នុងកិច្ចប្រជុំលើកទី ៤ នេះ ហើយបានសន្យានឹងផ្តល់សេចក្តីព្រាងរបាយការណ៍នៃកិច្ចប្រជុំនេះ នៅក្នុងរយៈពេល ២–៣ សប្តាហ៍ទៀត ។

១៨២ ប្រទេសឥណ្ឌូណេស៊ី តាងនាមជាភាគីដៃគូ បានសម្តែងការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អាជ្ញាធរក្រុង Incheon សាធារណៈរដ្ឋកូរ៉េ និងលេខាធិការដ្ឋាន EAAFP ចំពោះការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំលើកទី៤នេះ និងសូមថ្លែងអំណរគុណដល់អ្នកឧបត្ថម្ភកិច្ចប្រជុំនេះ (មានជប៉ុន រដ្ឋាភិបាលជាតិ) អ្នកស្ម័គ្រចិត្ត និងអ្នកជំនួយការ ផ្សេងៗទៀត ។

១៨៣. អនុប្រធានបានប្រកាសបិទ កិច្ចប្រជុំនេះ នៅវេលាម៉ោង ១៧ និង ១៥នាទី ។

**សេចក្តីសង្ខេបនៃវិធានការដែលបានលើកឡើង នៅក្នុងកិច្ចប្រជុំភាពជាភាគីដៃគូ លើកទី ៤**

| លរ វិធានការ | របៀបវារៈ សេចក្តីយោង | ការពិពណ៌នានៃវិធានការ | អ្នកដឹកនាំ ទទួលខុសត្រូវ | ម្ចាស់ជំនួយ |
|---|---|---|---|---|
| ១ | ១.៤ | រៀបចំវិញ្ញាបនបត្រនៃការចូលរួមជាភាគីដៃគូ EAAFP ថ្មី (សម្រាប់ អង្គការ WWT ) និងរៀបចំធ្វើបទបង្ហាញ | លេខាធិការដ្ឋាន | |
| ២ | ២.២.២ | វិធានការដែលត្រូវការ ដោយដៃគូ នៅក្នុងរបាយការណ៍របស់ក្រុមការងារសត្វស្លាបតំបន់ឆ្នេរ ចាំបាច់ត្រូវពិនិត្យឡើងវិញ និងអនុវត្ត។ | ប្រធានប្រតិបត្តិ | Ken Gosbell (AWSG) |
| ៣ | ២.២.៤ | សកម្មភាពរបស់ក្រុមការងារសត្វស្លាបសមុទ្រ ត្រូវធ្វើឱ្យសកម្មឡើងវិញ ។ | អង្គការជីវិតសត្វស្លាបអន្តរជាតិ | Noritaka Ichida (BI-Asia) |
| ៤ | ៣.១.១ | ផ្តល់ជំនួយការដល់ភាគីដៃគូ នៅក្នុងកាបង្កើត ការតែងតាំងបណ្តាញតំបន់ផ្លូវហោះហើរថ្មី រួមបញ្ចូលទាំងការជួយដោយផ្ទាល់ ដំណើរការឯកសារ ព័ត៌មានអំពី | លេខាធិការដ្ឋាន | ភាគីដៃគូ ជាច្រើន អាចត្រូវបានហៅឱ្យជួយ |

| | | | | |
|---|---|---|---|---|
| | | ផលប្រយោជន៍ នៃការចូលរួម ឧទាហរណ៍ នៃ ករណីសិក្សា គោលការណ៍ណែនាំ និងការគ្រប់គ្រង តំបន់សំរាប់សត្វស្លាបទឹក។ | | |
| ៥ | ៣.១.១ | ជួយរុស្ស៊ីដើម្បីផ្ទេរតំបន់ជាផ្លូវការពីបណ្តាញផ្សេងៗ ទៅបណ្តាញបច្ចុប្បន្ន ។ | ប្រធានប្រតិបត្តិ | Evgeny S. (រុស្ស៊ី) |
| ៦ | ៣.១.១ | គ្រប់ភាគីដៃគូទាំងអស់ បានបង្កើនចំនួន និងបង្ហាញអំពីសារៈសំខាន់ នៃទីតាំងរបស់សត្វស្លាបទឹក នៅក្នុងបណ្តាញតំបន់ផ្លូវហោះហើរ។ | រដ្ឋាភិបាលដៃគូ | គ្រប់ដៃគូផ្សេងៗ លេខាធិការដ្ឋាន |
| ៧ | ៣.១.៣ | បង្កើនពត៌មានអំពីតំបន់បណ្តាញផ្លូវហោះហើរ ដែលមាននៅលើគេហទំព័រ EAAFP និងដាក់ឱ្យភ្ជាប់ ជាមួយតំបន់ពាក់ព័ន្ធផ្សេងៗទៀត ដូចជា តំបន់រ៉ាមសារ និង AEWA ។ | លេខាធិការដ្ឋាន | រ៉ាមសារ CMS |
| ៨ | ៣.២១ | ទទួលបានឯកសារសំខាន់ៗ ដែលបានបកប្រែជាភាសាជាតិនៅក្នុងផ្លូវហោះហើរ និងដាក់លើគេហទំព័ររួចរាល់ | លេខាធិការដ្ឋាន | ជប៉ុន និង កូរ៉េ |
| ៩ | ៣.២១ | កម្រៃលើការងារបកប្រែឯកសារបន្ថែម ជាភាសាផ្សេងទៀត របស់ភាគីដៃគូផ្លូវហោះហើរ និងដាក់លើគេហទំព័រ របស់EAAFP ។ | លេខាធិការដ្ឋាន | កម្ពុជា និងដៃគូផ្សេងទៀត (មើលឯកសារ ៣.២១) |
| ១០ | ៣.២២ | ធ្វើឱ្យថ្មីគេហទំព័របច្ចុប្បន្ន ដោយរៀបចំបង្ហោះជាមួយនឹងMelbourne IT ត្រឹមខែមិនា ឆ្នាំ ២០១០ | ប្រធានប្រតិបត្តិ | |
| ១១ | ៣.២៣ | ដំណើរការធ្វើផែនការសំរាប់ការចូលរួម EAAFP នៅក្នុងសិក្ខាសាលាជាសាកលស្តីពីផ្លូវហោះហើរ ដូចដែលបានស្នើឡើង ដោយរ៉ាមសារ និងដៃគូដទៃទៀត រួមទាំង ការពិចារណាលើការរៀបចំនៅប្រទេសកូរ៉េ។ | ប្រធានប្រតិបត្តិ | រ៉ាមសារ អង្គការដីសើមអន្តរជាតិ និង CMS |
| ១២ | ៣.២៤ | ធ្វើផែនការសម្រាប់ព្រឹត្តិការណ៍ផ្សេងៗ ស្តីពីផ្លូវហោះហើរអូស្ត្រាលី-អាស៊ីខាងកើត នៅកិច្ចប្រជុំ CBD CoP10 ប្រទេសជប៉ុន ខែតុលា ឆ្នាំ ២០១០។ | ប្រទេសជប៉ុន លេខាធិការដ្ឋាន | លេខាធិការដ្ឋាន ដៃគូ |

| | | | | |
|---|---|---|---|---|
| ១៣ | ៣.២៤ | ផ្តល់ព័ត៌មានដល់ដៃគូអំពីវិធីសាស្ត្រដែលគេអាចពង្រឹងការអភិរក្សសត្វស្លាបទឹកទេសន្តរប្រវេសន៍ នៅកិច្ចប្រជុំ CBD CoP10 ។ | លេខាធិការដ្ឋាន | រ៉ាមសារ CMS |
| ១៤ | ៣.២ | ទំនាក់ទំនងជាមួយរ៉ាមសារអំពីកិច្ចសហការ និងឱកាសដើម្បីបង្ហាញព្រឹត្តិបត្រព័ត៌មានស្តីពីផ្លូវហោះហើរ ។ | លេខាធិការដ្ឋាន | រ៉ាមសារ |
| ១៥ | ៣.២៥ | ធ្វើការស្រាវជ្រាវប្រចាំឆ្នាំ និងពិនិត្យ ឡើងវិញ នៃវិទ្យាសាស្ត្រដែលពាក់ព័ន្ធ និងការបោះពុម្ពផ្សាយ ផ្សេងៗ អំពី បញ្ហា សត្វស្លាបទឹកដែលធ្វើទេសន្តរប្រវេសន៍ / ផ្លូវហោះហើរ និងដាក់ផ្សាយលើគេហទំព័រ ហើយធ្វើការបកប្រែភាសា ប្រសិនបើ ជាអាទិភាពខ្ពស់ ។ | លេខាធិការដ្ឋាន (មន្ត្រីវិទ្យាសាស្ត្រ) | ភាគីដៃគូទាំងអស់ |
| ១៦ | ៣.៣.២ | សកម្មភាពតម្រូវដោយភាគីដៃគូនៅក្នុងរបាយការណ៍គ្រប់គ្រងសត្វស្លាបតំបន់ឆ្នេរ ចាំបាច់ត្រូវធ្វើការពិនិត្យ និងអនុវត្ត | ប្រធានប្រតិបត្តិ | Ken Gosbell (AWSG) |
| ១៧ | ៣.៣.៤ | ពិភាក្សាបន្ថែមលើការគ្រប់គ្រង និងសំណើលើវិធីសាស្ត្រគាំទ្រការសំរេចចិត្ត (ឯកសារ ៣.៣.៤) និងផែនការសំរាប់សិក្ខាសាលាតូចៗ ក្នុងឆ្នាំ ២០១០ | Doug Watkins (WI), Ken Gosbell (AWSG), Samba Chan (Birdlife) ក្រុមការងារ ១ | ដៃគូផ្សេងៗ ទៀត (ឈ្មោះ ជាច្រើនបានផ្តល់ឱ្យ) លេខាធិការដ្ឋាន ដ្ឋាន |
| ១៨ | ៣.៣.៥ | សហប្រត្តិបត្តិការលើការធ្វើសារពើភ័ណ្ឌជីវះចម្រុះ (សត្វស្លាបទឹកទេសន្តរប្រវេសន៍ ) | ជប៉ុន | អង្គការដីសើម អន្តរជាតិ សត្វស្លាបអន្តរ ជាតិ |
| ១៩ | ៣.៣.៦ | អនុវត្តប្រតិបត្តិការ ភាពជាដៃគូផ្លូវហោះហើរអូស្ត្រាលី – អាស៊ីខាងកើត ក្រៅផ្លូវការ ដើម្បីពិនិត្យ ឡើងវិញ ការដៅពណ៌សម្គាល់សត្វស្លាបទឹក (គ្រប់ក្រុមទាំងអស់) នៅផ្លូវហោះហើរ និងកំណត់យន្តការសម្រាប់សម្របសម្រួលប្រសើរជាង របាយការណ៍និងការចែករំលែកព័ត៌មាន | អូស្ត្រាលី អង្គការដីសើម អន្តរជាតិ CMS ក្រុមការងារ (សត្វស្លាប តំបន់ឆ្នេរ Anatidae | ដៃគូផ្សេងៗ (ឈ្មោះ ជាច្រើនបានផ្តល់) លេខាធិការដ្ឋាន |

| | | | | |
|---|---|---|---|---|
| | | | និងក្រៀល) ក្រុមប្រតិបត្តិ ២ | |
| ២០ | ៣.៣.៦ | រក្សាបញ្ជីទំនាក់ទំនងមន្ត្រីសំរាប់គម្រោងការដៅសម្គាល់សត្វស្លាបទឹក នៅក្នុងផ្លូវហោះហើរ | លេខាធិការដ្ឋាន | អូស្រ្តាលី អង្គការដីសើមអន្តរជាតិ |
| ២១ | ៣.៣.៦ | រៀបចំឯកសារសំរាប់កិច្ចប្រជុំភាគីដៃគូនៅពេលបន្ទាប់ស្តីពីបញ្ហាសម្របសម្រួល និងជម្រើសទាក់ទងទៅនឹងការដៅពណ៌លើសត្វស្លាបទឹកទេសន្តរប្រវេសន៍ | អូស្រ្តាលី | |
| ២២ | ៣.៣.៦ | ផ្តល់ឯកសារស្តីពីគោលការណ៍ណែនាំសម្រាប់ការដៅពណ៌សម្គាល់បច្ចុប្បន្ន (សត្វស្លាបតំបន់ឆ្នេរ) ជូនដៃគូ និងដៃគូសំខាន់ៗ តាមការស្នើសុំ ។ | អូស្រ្តាលី | |
| ២៣ | ៣.៣.៧ | ពិនិត្យ ឡើងវិញនិងបង្កើតទម្រង់របាយការណ៍បន្ថែម (របាយការប្រចាំឆ្នាំសម្រាប់ MoP ) ដើម្បីសម្រុះសម្រួល បញ្ហាដែលលើកឡើងដោយអ្នកប្រើប្រាស់ | លេខាធិការដ្ឋាន | អូស្រ្តាលី |
| ២៤ | ៣.៤.១ | ធ្វើការតាមដានដៃគូដែលចូលរួមកិច្ចប្រជុំលើកទី ៤ ជាពិសេស នៅតំបន់ដែលសិក្ខាសាលាជាតិត្រូវបានរៀបចំឡើង ។ | ប្រធានប្រតិបត្តិ | អង្គការដីសើមអន្តរជាតិ អង្គការជីវិតសត្វស្លាបអន្តរជាតិ ជប៉ុន |
| ២៥ | ៣.៤.២ | លើកទឹកចិត្តដល់ការបង្កើត កិច្ចប្រជុំភាគីជាតិ ឬភាពជាដៃគូស្តីពីសត្វស្លាបទឹកទេសន្តរប្រវេសន៍ | លេខាធិការដ្ឋាន | កូរ៉េ ជប៉ុន អង្គការដីសើមអន្តរជាតិ |
| ២៦ | ៣.៥.១ | ធ្វើការពិចារណាថា តើដៃគូជាច្រើនទៀត អាចជាផ្នែកនៃ កម្មវិធីកិច្ចសហប្រត្តិបត្តិការធំជាងមួយ នៃសកម្មភាពរបស់ភាពជាដៃគូ ក្នុងតំបន់អេកូនៃសមុទ្រលឿង | អង្គការដីសើមអន្តរជាតិ | កូរ៉េ ចិន ជប៉ុន និងដៃគូទាំងអស់ |
| ២៧ | ៣.៥.២ | ធ្វើការអង្កេតគំរូដែលមានស្រាប់ (AEWAI etc.) និងពិចារណាលើកម្រិតសមស្រប រី ប្រភេទនៃការអនុម័ត | Jim Harris (ICF) ក្រុមប្រតិបត្តិ ៣ | Baz Hughes (W&W), Bert Lenten (AEWA), |

| | | | | |
|---|---|---|---|---|
| | | យល់ព្រម ដោយ EAAFP នូវសកម្មភាពពាក់ព័ន្ធ ដូចជា ផែនការសកម្មភាព សំរាប់ប្រភេទដែលទទួលរងការ គម្រាមកំហែង ។ | | Taej M. (WI) Evgeny S. រុស្ស៊ី |
| ២៨ | ៣.៥.៣ | ភា្ជាឯកសារពាក់ព័ន្ធផ្សេងៗ ផែនការសកម្មភាព អន្តរជាតិ ដែលបង្កើតនាពេលថ្មីៗ របស់លេខាធិការដ្ឋាន សំរាប់ពពួកវិពេរ និងកុកចំពុះស្លាបព្រា | អង្គការជីវិតសត្វស្លាបអន្តរជាតិ CMS | |
| ២៩ | ៣.៥.៤ | បង្ហាញទម្រង់ពិតប្រាកដ នៃការអនុម័តយល់ព្រម ឬ ការដាក់បញ្ចូលគ្នានៃ EAAFP ជាមួយនឹងគំនិតផ្តួចផ្តើម រៀបចំផែនការសកម្មភាពអន្តរជាតិសំរាប់ប្រភេទ Spoonbilled Sandpiper និង Scalysided Merganser | លេខាធិការដ្ឋាន | Jim Harris (ICF) និង ក្រុមប្រតិបត្តិ ៣ |
| ៣០ | ៤.១ | ភ្ជាប់គេហទំព័រ EAAFP ជាមួយនឹងគេហទំព័រដៃគូនីមួយៗ | លេខាធិការដ្ឋាន | |
| ៣១ | ៤.២ | សរសេរអំពីការពន្យល់នៃស្ថានភាព EAAFP និងបង្ហោះលើគេហទំព័ររបស់ EAAFP | ប្រធានប្រតិបត្តិ | គណៈកម្មការគ្រប់គ្រង |
| ៣២ | ៥.១ | ធ្វើឱ្យភាគីដៃគូបានដឹងបន្ថែមទៀត (តាមរយៈ គេហ–ទំព័រ EAAFP ) អំពីមូលនិធិខ្នាតតូច ដែលអាចរកបាន សំរាប់តំបន់ផ្លូវហោះហើរ ។ | ប្រធានប្រតិបត្តិ | Bena Smith (WWF) រាមសារ RRCEA |
| ៣៣ | ៥.១ | ការបែងចែកនៃថវិការបស់លេខាធិការដ្ឋាន ឆ្នាំ២០១០ សំរាប់គំរោង ឬ សកម្មភាពផ្សេងៗ | ប្រធានប្រតិបត្តិ | គណៈកម្មការគ្រប់គ្រង |
| ៣៤ a | ៦.៣ | សមាជិកដែលមានស្រាប់ នៃគណៈកម្មការគ្រប់គ្រង នៃលេខាធិការដ្ឋាន គួរបន្តការរបស់ខ្លួន | សមាជិកទាំង ៨ នៃ MC | |
| ៣៤ b | ៦.២ | បញ្ចប់បញ្ជីនៃបញ្ហា EAAFP ដែលចាំបាច់ត្រូវមានការ អនុញ្ញាត្ត (ហត្ថលេខា) និងបញ្ជាក់ថា តើមួយណាដែល ត្រូវធ្វើឡើង ដោយប្រធានប្រតិបត្តិ ឬប្រធានអង្គប្រជុំ | ប្រធានប្រតិបត្តិ | គណៈកម្មការគ្រប់គ្រង (MC) |
| ៣៥ | ៦.៣ | ពិនិត្យឡើងវិញ ធ្វើបច្ចុប្បន្នភាព និងបញ្ចប់សេចក្តីព្រាង ថ្មី នៃល័ក្ខខ័ណ្ឌការងារសំរាប់គណៈកម្មការគ្រប់គ្រង នៃ លេខាធិការដ្ឋាន | អនុគណកម្មការ (Doug Alcorn, Doug Hykle, Doug | ប្រធានប្រតិបត្តិ ប្រធានអង្គប្រជុំ (កូរ៉េ) អនុប្រធាន |

| | | | | |
|---|---|---|---|---|
| | | | Watkins) ក្រុមប្រតិបត្តិ ៤ | អង្គប្រជុំ (ជប៉ុន) |
| ៣៦ | ៦.៤ | ផ្តល់គំនិតបន្ថែមនូវអ្វីដែលEAAFP ប្រាថ្នាចង់បាន ដើម្បីសម្រេច តាមរយៈការឧបត្ថម្ភ ដៃគូសំខាន់ៗ ដើម្បីចូលរួម កិច្ចប្រជុំ និងកែប្រែគោលការណ៍ណែនាំ ការជួយឧបត្ថម្ភ ឱ្យបានសមស្រប ។ | ប្រធានប្រតិបត្តិ | Doug Watkins (WI) |
| ៣៧ | ៦.៥ | ពិនិត្យ ប្រតិទិន ឆ្នាំ២០១០ និងតារាងពេលវេលា ការងារនៃដៃគូ និងអង្គការអន្តរជាតិ ដែលពាក់ព័ន្ធ ដើម្បីកំណត់ឱកាសរៀបចំព្រឹត្តិការ EAAFP និង សំរាប់មនុស្សសំខាន់ដែលមិនអាចចូលរួម | លេខាធិការដ្ឋាន | |
| ៣៨ | ៦.៥ | ពិនិត្យ ឡើងវិញសេចក្តីព្រាងផែនការរបស់លេខាធិការដ្ឋាន ដើម្បី ធ្វើឱ្យស៊ីសង្វាក់គ្នានឹង សកម្មភាពដែលបានលើកឡើង ពី កិច្ចប្រជុំលើកទី ៤ និងលប់ចោល ផងដែរ ចំពោះកាតព្វកិច្ចណា ដែលមិនមែនជា កាតព្វកិច្ចរបស់លេខាធិការដ្ឋាន និងបន្ថែមវិធានការ (ថ្ងៃ និងផ្សេងៗ) នៃការខិតខំប្រឹងប្រែង សំរាប់ កាតព្វកិច្ចនីមួយៗ ។ | ប្រធានប្រតិបត្តិ | |
| ៣៩ | ៦.៦ | ផ្តល់ពត៌មានជូនរដ្ឋាភិបាលក្រុង Incheon អំពីការ អនុម័តយល់ព្រមរបស់ដៃគូ សម្រាប់ការបែងចែក ឡើងវិញ ថវិកា ឆ្នាំ ២០១០ ។ | ប្រធានប្រតិបត្តិ | |
| ៤០ | ៦.៦ | ការកែប្រែនៃឯកសារថវិកាប្រតិបត្តិការរបស់ លេខាធិការដ្ឋាន ឆ្នាំ ២០១០ | ប្រធានប្រតិបត្តិ | |
| ៤១ | ៧ | សម្រេចអំពីរបៀបឆ្លើយតបទៅនឹង បទបង្ហាញដែលធ្វើ ដោយបណ្តាញអង្គការមិនមែនរដ្ឋាភិបាលជីសើម កូរ៉េ ដែលទាក់ទងនឹងការគម្រោមកំហែងលើតំបន់ទន្លេណាក់ ដុង (Nakdong Estuary) (តំបន់បណ្តាញ) | ប្រធានប្រតិបត្តិ | កូរ៉េ និង គណៈកម្មការ គ្រប់គ្រង |
| ៤២ | ៧ | ជម្រុញ ការប្រារព្ធទិវាសត្វស្លាបទេសន្តរប្រវេសន៍ | លេខាធិការដ្ឋាន | CMS/AEWA |

| | | | | |
|---|---|---|---|---|
| | | នៅក្នុងផ្លូវហោះហើរនេះ | | |
| ៤៣ | ៧ | រៀបចំគំនិតគម្រោងស្នើសុំថ្មី ជូនអង្គការ GEF ស្តីពីសត្វស្លាបទឹក នៅក្នុង EAAFP ដោយផ្អែកលើការស្នើសុំមុនៗ ។ | Taej Mundkur (អង្គការដីសើមអន្តរជាតិ) | ប្រធានប្រតិបត្តិ |
| ៤៤ | ៨ | ពិចារណាអំពីការរៀបចំកិច្ចប្រជុំក្រុមការងារ (និងក្រុមដែលពាក់ព័ន្ធ) ដែលមានទំនាក់ទំនងនឹងកិច្ចប្រជុំភាគីដៃគូរ នៅពេលក្រោមនេះ ។ | លេខាធិការដ្ឋាន | ប្រធាន WGs |
| ៤៥ | ៨ | ការពិចារណាលើការផ្តល់ឱ្យកម្ពុជា ធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំលើកទី ៥ នៅពេលដែលការយល់ព្រមផ្ទៃក្នុង ត្រូវបានធ្វើឡើង ដោយតំណាងក្រសួង នៅក្នុងកិច្ចប្រជុំ លើកទី៤ ។ | ប្រធានប្រតិបត្តិ | គណៈកម្មការគ្រប់គ្រង |
| ៤៦ | ៨ | ទាក់ទងសហរដ្ឋអាមេរិចអំពីលទ្ធភាពធ្វើជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំដៃគូ អនាគត នៅអាឡាស្កា (២០១១ ឬឆ្នាំក្រោយទៀត) | ប្រធានប្រតិបត្តិ | សហរដ្ឋអាមេរិច (Doug Alcorn) |
| ៤៧ | ៣.៣ និង ៣.៤ | ផលិតបច្ចុប្បន្នភាពសៀវភៅស្តីពីការធ្វើអត្តសញ្ញាណកម្មសត្វស្លាបតំបន់ឆ្នេរ (WWF) សំរាប់ ប្រើប្រាស់ក្នុងប្រទេស ដែលបានជ្រើសរើសជាផ្លូវហោះហើរ ។ | ប្រទេសអូស្ត្រាលី | លេខាធិការដ្ឋាន |